# អភិណ្ហបច្ចវេក្ខណ


រៀបរៀងដោយ

ភិក្ខុ ងិន កេន ឥន្ទប្បញ្ញោ

វត្តពោធិវង្ស ប្រទេសបារាំង



បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

# អភិណ្ហបច្ចវេក្ខណ

៙៚៙

រៀបរៀងដោយ

ភិក្ខុ ងិន កេន ឥន្ទបញ្ញោ

វាយកុំព្យូទ័រ និង ចាត់ចែងដោយ

ភិក្ខុ ពេជ្រ សាម៉ុន


បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស

ប្រទេសបារាំង

ព,ស, ២៥៥៥ គ,ស, ២០១១

# អារម្ភកថា

៙

សៀវភៅនេះ សរសេរលើកដំបូង ជាសំនួនធម្ម-ទេសនា ដាក់ឈ្មោះថា ឋានសូត្រ តាមគម្ពីរព្រះត្រៃបិដក បោះពុម្ព ចែកជាធម្មទានដោយ ឧបាសក យ៉ាន់ យ៉េន និង ឧបាសក លិម ជិន ។

បន្ទាប់មក កែសម្រួល ជាសេចក្ដីធម្មតា ដាក់ឈ្មោះថា អភិណ្ហបច្ចវេក្ខណៈ តាមការនិយម បោះពុម្ពចែកជាធម្មទាន ដោយ លោក ទា ឡឹក ឆាយ ។

ឥឡូវនេះ ជាលើកក្រោយបំផុត សរសេរបន្ថែម សម្រេច រក្សាទុកនូវឈ្មោះថា អភិណ្ហបច្ចវេក្ខណៈ ដដែល ប៉ុន្តែ មានខ្លឹមសារច្រើនជាងមុន ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ សំរាប់លោក អ្នក សិក្សាបដិបត្តិធម៌ តអង្វែងទៅ ៕

វត្តពោធិវង្ស ថ្ងៃទី ១២ មីនា ២០១១

ភិក្ខុ ងិន កេន

# អភិណ្ហបច្ចវេក្ខណ

❋ ❋ ❋

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## អភិណ្ហបច្ចវេក្ខណធម៌

*ធម៌ដែលបុគ្គលគប្បីពិចារណារឿយៗ*

ក្នុងគម្ពីរ សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ព្រះលោកនាថ សម្មាសម្ពុទ្ធ សម្តែងថា បញ្ចិមានិ ភិក្ខវេ ឋានានិ អភិណ្ហំ បច្ចវេក្ខិតព្វានិ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ ម្នាលភិក្ខុ-ទាំងឡាយ ឋានៈ (ធម៌ជាទីតាំងតម្កល់ចិត្ត) ៥ យ៉ាង នេះ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គប្បីពិចារណាឲ្យរឿយៗ [១] ។ ឋានៈ ៥ យ៉ាងនេះ គឺ ៖

---

(១)- ព្រះគន្ថរចនាចារ្យ ហៅ ធម៌នេះថា ឋានសូត្រ ប៉ុន្តែ អ្នកជំនាន់ក្រោយ និយមហៅធម៌នេះថា អភិណ្ហបច្ចវេក្ខណធម៌ ៕

១-ជរាធម្មោម្ហិ ជរំ អនតីតោ អាត្មាអញមានជរា ជាធម្មតា មិនកន្លងជរាទៅបានឡើយ ។

២-ព្យាធិធម្មោម្ហិ ព្យាធិំ អនតីតោ អាត្មាអញមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ។

៣-មរណធម្មោម្ហិ មរណំ អនតីតោ អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ។

៤-សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្មាអញមានសេចក្តីព្រាត់ប្រាសនិរាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង ។

៥-កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ(២) គឺជាអ្នកទទួលមត៌កនៃកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹងអាស្រ័យ អាត្មាអញនឹងធ្វើនូវកម្មណា ល្អក្តី អាក្រក់

---

(២)- អ្នកខ្លះប្រែថា មានកម្មជាមត៌ក ដូចនេះ ក៏មាន ។

ក្តី ទឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ។

**ការពិចារណាយ៉ាងនេះមានប្រយោជន៍អ្វី ?**

ព្រះពុទ្ធ សម្តែងថា ៖

១-មនុស្សយើង តែងមានសេចក្តី ស្រវឹងជាធម្មតា យោព្វនមទៈ ស្រវឹងក្នុងវ័យ គឺស្រវឹងថា អញនៅក្មេង អញនៅកម្លោះ ក្រមុំ ដោយអាស្រ័យសេចក្តី ស្រវឹងនោះ គេរមែងធ្វើទុច្ចរិត ដោយ កាយ វាចា ចិត្ត ។ បើគេបានពិចារណារឿយៗថា អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ដូចនេះហើយ គេនឹងលះបានទាំងស្រុងនូវសេចក្តីស្រវឹងក្នុងវ័យនោះ ឬ យ៉ាងហោចណាស់ ក៏ធ្វើឲ្យវាស្រាលស្តើងបានខ្លះដែរ ។

ជរា ឬ ចំណាស់ មាន 2 យ៉ាងគឺ : 1-បដិច្ឆន្នជរា ជរាបិទបាំង បើមិនប្រើបញ្ញា មិនដឹងថា ជរាទេ គឺវាប្រែពីតូចមកធំ ពីទារកមកកម្លោះ ក្រមុំ នេះហៅថា ជរា រឹងប៉ឹង ។ 2-អប្បដិច្ឆន្នជរា ជរាមិនបិទបាំង កូនក្មេងក៏យល់បានដែរ វាប្រែពីសក់ខ្មៅ មកសក់ស ប្រែពី

ស្បែកតឹង មកស្បែកជ្រួញ ប្រែពីខ្លួនត្រង់ មកខ្លួនកោង នេះហៅថា ជរាទុក្ខទោម ។ ជរា ជាច្បាប់របស់ធម្មជាតិ ជាច្បាប់របស់សង្ខារធម៌ អ្វីតែកើតមានឡើងហើយ ត្រូវតែមានជរា... គ្មានអ្វីដែលកើតមានហើយ មិនជរា ឬ កន្លងជរានោះ បានឡើយ ។

២-មនុស្សយើង តែងមានសេចក្ដីស្រវឹង ជាធម្មតា អារោគ្យមទៈ ស្រវឹងក្នុងភាពជាអ្នកមិនមានរោគ គឺស្រវឹងថា អញអត់មានជំងឺ អត់មានរោគអីទេ ដោយអាស្រ័យសេចក្ដីស្រវឹងនោះ គេរមែងធ្វើ ទុច្ចរិត ដោយ កាយ វាចា ចិត្ត ។ បើគេបានពិចារណារឿយៗថា អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ដូចនេះហើយ គេនឹងលះបានទាំងស្រុង នូវសេចក្ដីស្រវឹងក្នុងភាពជាអ្នកមិនមានរោគនោះ ឬ យ៉ាងហោចណាស់ ក៏ធ្វើឲ្យវាស្រាលស្តើងបានខ្លះដែរ ។

ព្យាធិ ប្រែថា ជំងឺ តម្កាត់ ។ ជំងឺ កើតចេញមកពីក្នុងរាងកាយជារោគផ្សេងៗ តម្កាត់ កើតមកពីក្រៅរាងកាយ

ពស់ចឹក ខែ្មកឈើធ្លាក់លើ ជំពប់ដុំថ្ម ជាដើម ។ នរណា ក៏មានព្យាធិដែរ បើមិនច្រើន ក៏ តិច អ្នកដែលកន្លងព្យាធិទៅបាននោះ គ្មានទេ ។

៣-មនុស្សយើង តែងមានសេចក្តីស្រឡាញ់ ជាធម្មតា **ជីវិតមនៈ** ស្រឡាញ់ក្នុងជីវិត អញនៅមានអាយុវែងតទៅទៀត អញមិនទាន់ស្លាប់ទេ ដោយអាស្រ័យសេចក្តីស្រឡាញ់នោះ គេរមែងធ្វើទុច្ចរិតដោយ កាយ វាចា ចិត្ត ។ បើគេបានពិចារណារឿយៗថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ ដូចនេះហើយ គេនឹងលះបានទាំងស្រុងនូវសេចក្តីស្រឡាញ់ក្នុងជីវិតនោះ ឬ យ៉ាងហោចណាស់ ក៏ធ្វើឲ្យវាស្រាលស្តើងបានខ្លះដែរ ។

សេចក្តីពិត ជីវិតរបស់មនុស្សយើង មានប្រមាណតិចណាស់ ប្រៀបដូចទឹកសន្សើម ថ្ងៃរះឡើងតែបន្តិចរីងស្ងួតអស់ហើយ ។ បច្ច័យនៃសេចក្តីស្លាប់របស់ជីវិត មានច្រើនណាស់ ដកដង្ហើមមិនស្រួលស្លាប់, ដង្ហើមចូល មិនចេញ ស្លាប់, ដង្ហើមចេញ មិនចូល ស្លាប់... ដូចនេះ នរណានឹងកន្លងសេចក្តីស្លាប់ទៅបាន គ្មាននរណាកន្លងផុតបានទេ

គ្មានទីណា អ្នកកើតមកហើយមិនស្លាប់ទេ កើតមកប៉ុន្មាន ស្លាប់ទៅវិញប៉ុណ្ណឹងទាំងអស់ ។ គ្រប់ជីវិត គ្រប់ការកើត ត្រូវតែជួបនឹងស្លាប់ និង រលត់ ជាធម្មតា ។ គ្មានអ្នកទ្រូង សេចក្ដីស្លាប់ទៅបានឡើយ ។ យំកិញ្ចិ សមុទយធម្មំ របស់ណានីមួយដែលមានការកើតឡើង សព្វន្តំ និរោធធម្មំ របស់នោះត្រូវរលត់ទៅវិញ ទាំងអស់ ។

៤-មនុស្សយើង តែងមានឆន្ទាគៈ សេចក្ដីត្រេកត្រអាលចំពោះសត្វ និង សង្ខារ[៣] ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ។ ដោយសេចក្ដីត្រេកត្រអាលនោះ មនុស្សរមែងធ្វើទុច្ចរិត ដោយ កាយ វាចា ចិត្ត ។ បើគេបានពិចារណារឿយៗថា អាត្មាអញ មានសេចក្ដីព្រាត់ប្រាសនិរាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួងដូចនេះហើយ គេនឹងលះបានទាំងស្រុងនូវឆន្ទាគៈ នោះ ឬយ៉ាងហោចណាស់ ក៏ធ្វើឲ្យវាស្រាលស្តើងបានខ្លះដែរ ។

---

[៣]- ក្នុងទីនេះ មនុស្ស និង សត្វ មានជីវិត ហៅថា សត្វ, កាមគុណ៥ ឬ របស់ប្រើប្រាស់ គ្មានជីវិត ហៅថា សង្ខារ ។

អ្វីទាំងអស់ ដែលកើតមានហើយ ត្រូវតែរលត់ទៅ វិនាសទៅ សាបសូន្យទៅ ជាធម្មតា ជួនកាល យើងរលត់មុនវា ជួនកាល វារលត់មុនយើង ជួនកាលក៏ព្រាត់ប្រាសរស់ ជួនកាលក៏ព្រាត់ប្រាសស្លាប់ មិនទៀងទេ ស្រេចលើហេតុបច្ច័យ ប៉ុន្តែ ត្រូវតែជួបនឹងការព្រាត់ប្រាស ជៀសមិនផុតទេ ។ វត្ថុ ជាទីស្រឡាញ់ ក៏ព្រាត់ប្រាស វត្ថុមិនជាទីស្រឡាញ់ក៏ព្រាត់ប្រាស វាព្រាត់ប្រាសតែទាំងអស់ ទាំងពីរយ៉ាងហ្នឹង ប៉ុន្តែ វត្ថុមិនជាទីស្រឡាញ់ គេមិននិយាយព្រោះអ្វី ? ព្រោះវត្ថុមិនជាទីស្រឡាញ់ យើងមិនត្រេកត្រអាល មិនមានឆន្ទរាគៈ ឯងវិនាសទៅ អញក៏មិនកើតទុក្ខ ។ ចំណែកវត្ថុជាទីស្រឡាញ់ យើងត្រេកត្រអាល យើងមានឆន្ទរាគៈ បើឯងវិនាសទៅ អញកើតទុក្ខ... ។ តួនាំឲ្យកើតទុក្ខ គឺ ឆន្ទរាគៈ សេចក្ដីត្រេកត្រអាលហ្នឹងឯង ។ បើគេពិចារណារឿយៗ គេយល់សេចក្ដីពិតនេះទៅ គេនឹងស្រាលទុក្ខ បើលះឆន្ទរាគៈ នោះបាន គេអស់ទុក្ខទាំងស្រុងតែម្ដង ។

៥-មនុស្សយើង តែងធ្វើកម្មដោយ កាយ វាចា ចិត្ត ជានិច្ច បើមិនធ្វើអាក្រក់ ក៏ធ្វើល្អដែរ តែភាគច្រើន គេធ្វើកម្ម

អាក្រក់ ដែលហៅថា ទុច្ចរិត ដោយ កាយ វាចា ចិត្ត ។ គេមិនយល់ច្បាប់របស់កម្មផលទេ ជួនកាល គេយល់ខុសថា កម្មអាក្រក់ ក៏គ្មានឲ្យផលអាក្រក់អ្វីដែរ ធ្វើយ៉ាងណាឲ្យតែបានទ្រព្យច្រើន ឲ្យតែបានសប្បាយ គឺជាការល្អហើយ ម៉្លោះហើយ គេរឹតតែធ្វើកម្មអាក្រក់ច្រើនឡើងៗថែមទៀត ។

បើគេបានយល់ច្បាប់កម្មផលថា កម្មជារបស់ខ្លួន កម្មជាមត៌ក កម្មជាអ្នកឲ្យកំណើត កម្មជាផៅពង្ស កម្មជាទីពឹងអាស្រ័យ យើងធ្វើនូវកម្មណា ល្អក្តី អាក្រក់ក្តី យើងត្រូវទទួលផលនៃកម្មនោះ ។ សុខ ទុក្ខ កើតមកពីកម្មរបស់ខ្លួន មិនមែនឥតហេតុផល ឬ ព្រះអាទិទេពណាបណ្តាលឲ្យទេ ។ បើគេបានពិចារណារឿយៗយ៉ាងនេះ គេនឹងលះបានទាំងស្រុងនូវអំពើទុច្ចរិត ឬ យ៉ាងហោចណាស់ ក៏ធ្វើឲ្យរាស្រាលស្តើងបានខ្លះដែរ ។

## ការពិចារណារបស់ព្រះអរិយសាវក

អរិយសាវក អ្នកបានសេពគប់សប្បុរស បានស្តាប់ធម៌របស់សប្បុរស រមែងមានសេចក្តីយល់ដឹងបានច្រើន

លោកគិតបានវែងឆ្ងាយ ពិចារណាបែបទូលាយថា ជរាធម៌ ព្យាធិធម៌ មរណធម៌ មិនមែនមានតែអាត្មាអញម្នាក់ឯងទេ មានគ្រប់សព្វសត្វទូទៅទាំងអស់ គ្រប់ទីកន្លែងទាំងអស់គ្រប់កាលទាំងអស់ ។ មនុស្ស សត្វ ទេវតា មារ ព្រហ្ម ក្នុងអតីតកាលក្តី ក្នុងបច្ចុប្បន្នកាលក្តី ក្នុងអនាគតកាលក្តី ក៏មានធម៌នេះដូចគ្នាទាំងអស់ សត្វលោក កំពុងទៅ កំពុងមក កំពុងច្យុត កំពុងកើត សុទ្ធតែមានធម៌នេះដូចគ្នាទាំងអស់ ។ នេះជាច្បាប់របស់ធម្មជាតិ ជាច្បាប់របស់ធម៌ ជាច្បាប់របស់សង្ខារ ជាច្បាប់របស់ព្រះត្រៃលក្ខណ៍ ។ ធម្មតារបស់វាអញ្ចឹង គ្មាននរណា កន្លងផុត ធម៌នេះបានទេ។

នានាភាវធម៌ វិនាភាវធម៌ គឺធម៌ព្រាត់ប្រាស ធម៌វិនាស ចាកសត្វ និង សង្ខារ មិនមែនមានតែអាត្មាអញម្នាក់ឯងទេ មានគ្រប់សព្វសត្វទូទៅទាំងអស់ គ្រប់ទីកន្លែងទាំងអស់ គ្រប់កាលទាំងអស់ ។ល។ នេះជាច្បាប់របស់ធម្មជាតិ ជាច្បាប់របស់ធម៌ ជាច្បាប់របស់សង្ខារ ជាច្បាប់របស់ព្រះត្រៃលក្ខណ៍ ។ ធម្មតារបស់វាអញ្ចឹង គ្មាននរណា កន្លងផុតធម៌នេះបានទេ ។

អរិយសាវក តែងពិចារណារឿយៗថា កម្មជារបស់ខ្លួន កម្មជាមត៌ក កម្មជាអ្នកឲ្យកំណើត កម្មជាផៅពង្ស កម្មជាទីពឹងអាស្រ័យ បុគ្គលធ្វើនូវកម្មណា ល្អក្តី អាក្រក់ក្តី ត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ។ ការទទួលនូវផលនៃ កម្មនោះមិនមែនមានតែអាត្មាអញម្នាក់ឯងទេ មានគ្រប់សព្វសត្វទូទៅទាំងអស់ គ្រប់ទីកន្លែងទាំងអស់ គ្រប់កាលទាំងអស់ ។ល។ នេះជាច្បាប់ធម្មជាតិ ជាច្បាប់របស់ធម៌ ជាច្បាប់របស់កម្ម ។ ធម្មតារបស់វាអញ្ចឹង គ្មាននរណាកន្លងផុតច្បាប់របស់កម្មបានទេ ។

អរិយសាវក កាលបានពិចារណាធម៌ ៥ ប្រការនេះរឿយៗ អប្បមាទ សេចក្តីមិនប្រមាទកើតឡើង ហិរិ សេចក្តីខ្មាសបាប និង ឱត្តប្ប សេចក្តីខ្លាចបាបកើតឡើង បន្ទាប់មកសីលកើតឡើង សមាធិ និង បញ្ញា ក៏កើតឡើងជាលំដាប់គ្នាបានឈ្មោះថា មគ្គជាលោកិយកើតឡើង កាលសេពគប់បដិបត្តិមគ្គជាលោកិយច្រើនឡើងៗ មគ្គជាលោកុត្តរក៏កើតឡើងលះសំយោជនៈបាន ព្រមទាំងកំចាត់អនុសយក្កិលេសឲ្យវិនាសទៅ បានសម្រេចមគ្គផលដល់ព្រះនិព្វាន

ជាបរិយោសាន ៗ

## សំយោជនៈ ១០

កិលេស ជាគ្រឿងចងសត្វទុកក្នុងភពវដ្តសំសារ ហៅថា សំយោជនៈ មាន ១០ គឺៈ

១-សក្កាយទិដ្ឋិ សេចក្ដីយល់ឃើញថាជាតួខ្លួន

២-វិចិកិច្ឆា សេចក្ដីសង្ស័យ មិនច្បាស់ក្នុងចិត្ត

៣-សីលព្វតបរាមាស សេចក្ដីប្រកាន់ក្នុងសីល និងវត្ត ដែលគ្រាន់តែធ្វើតាមៗគ្នា

៤-កាមរាគ សេចក្ដីត្រេកត្រអាលក្នុងកាមគុណ

៥-បដិឃ សេចក្ដីថ្នាំងថ្នាក់ចិត្តក្នុងអារម្មណ៍

៦-រូបរាគ សេចក្ដីជាប់ចិត្តក្នុងរូបឈាន ក្នុងរូបធម៌ដ៏ប្រណីត ឬ ក្នុងរូបភព

៧-អរូបរាគ សេចក្ដីជាប់ចិត្តក្នុងអរូបឈាន ក្នុងអរូបធម៌ ឬ ក្នុងអរូបភព

៨-មានៈ សេចក្ដីប្រកាន់ខ្លួន

៩-ឧទ្ធច្ច សេចក្ដីអណ្ដែតអណ្ដូង

១០-អវិជ្ជា សេចក្តីមិនដឹងតាមសេចក្តីពិត ។

## អនុស័យ ៧

កិលេស ដែលដេកត្រាំនៅក្នុងសន្តានចិត្តរបស់សត្វ ហៅថា អនុស័យ មាន ៧ គឺ ៖

១-កាមរាគ សេចក្តីត្រេកត្រអាលក្នុងកាមគុណ

២-បដិឃ សេចក្តីថ្នាំងថ្នាក់ចិត្តក្នុងអារម្មណ៍

៣-ទិដ្ឋិ សេចក្តីយល់ឃើញខុស

៤-វិចិកិច្ឆា សេចក្តីសង្ស័យ មិនច្បាស់ក្នុងចិត្ត

៥-មានៈ សេចក្តីប្រកាន់ខ្លួន

៦-ភវរាគ សេចក្តីត្រេកត្រអាលក្នុងភព

៧-អវិជ្ជា សេចក្តីមិនដឹងតាមសេចក្តីពិត ។

បុគ្គលអ្នកពិចារណារឿយៗ នូវអកិណ្ហបច្ចវេក្ខណធម៌ ៥ យ៉ាង បដិបត្តិច្រើនឡើងៗ ក្នុងទីបំផុត លោកុត្តរមគ្គកើតឡើង កំចាត់នូវសំយោជនៈ ១០ និង អនុស័យ ៧ នេះអស់រលីង បានសម្រេចមគ្គផលព្រះនិព្វាន ។

## មគ្គកើតឡើងដូចម្ដេច ?

អភិញ្ញប្បច្ចវេក្ខណធម៌នេះ បើគេគ្រាន់តែអាន ដូចជាធម្មតា ៗ ងាយ ៗ រាក់ ៗ ប៉ុន្តែ បើគេពិចារណារឿយ ៗ ទៅធម៌នេះ មានជម្រៅ មានខ្លឹមសារណាស់ ។ អ្នកពិចារណាធម៌ ៥ យ៉ាងនេះ រមែងបានយល់ដឹងច្បាប់របស់ធម្មជាតិ កើត ចាស់ ឈឺ ស្លាប់ ការព្រាត់ប្រាស និង ច្បាប់របស់កម្មផល។ គេនឹងប្រែទៅជាអ្នកភ្ញាក់រលឹក មិនមានសេចក្ដីប្រមាទ សង្វាតសាងសេចក្ដីល្អ កុសលកម្ម មាន ហិរិ ខ្មាសបាប ឱត្តប្ប ខ្លាចបាប ចេះធ្វើបុណ្យទាន រក្សាសីល ចំរើនភាវនា សមាធិ បញ្ញា ដែលជាលោកិយមគ្គរឿយ ៗ ជាលំដាប់ទៅ។ កាលបើគេចំរើនលោកិយមគ្គនេះច្រើនឡើង១ វិបស្សនា-បញ្ញា ក៏កើតកាន់តែច្រើនឡើង ៗ ដឹងច្បាស់រឿង កើត ចាស់ ឈឺ ស្លាប់ ឬ អនិច្ចំ ទុក្ខំ អនត្តា កាន់តែច្បាស់ឡើង១ ជម្រុញចិត្តគេឲ្យឆ្លងពីលោកិយមគ្គ ទៅជា លោកុត្តរមគ្គ កាលគេសេព គឺ ចំរើនលោកុត្តរមគ្គនោះច្រើនឡើង១ សំយោជនៈ និង អនុស័យ ក៏វិនាសអស់រលីង បាន សម្រេចមគ្គផលដល់ទីបំផុតទុក្ខ គឺ ព្រះនិព្វានហោង ។

## បហានៈ ៥

ការលះកិលេស ហៅថា បហានៈ មាន ៥ គឺ ៖

**១-វិក្ខម្ភនប្បហាន** ការលះកិលេសបានដោយការសង្កត់ទុក គឺ ពេលដែលចិត្តស្ថិតនៅក្នុងឈាន កិលេសនីវរណធម៌ ស្ងប់មួយរយៈ ។

**២-តទង្គប្បហាន** ការលះកិលេសដោយអង្គធម៌នោះ គឺធម៌ដែលជាទំនាស់នឹងគ្នា ឧទាហរណ៍ ឈ្នះក្រោធដោយ-មិនក្រោធ ឈ្នះមិនល្អដោយល្អ ឈ្នះកំណាញ់ដោយឲ្យទាន ឈ្នះពាក្យឡេះឡោះដោយពាក្យពិត ឬ លះសក្កាយទិដ្ឋិដោយការវែកញែកនាមរូប ។ល។ ទាំងអស់នេះ សុទ្ធតែលះបានមួយរយៈៗ មិនទាន់លះបានដាច់ខាតជ្រះស្រឡះទេ ។

**៣-សមុច្ឆេទប្បហាន** ការលះកិលេសបានដោយដាច់ខាត គឺលះដោយលោកុត្តរមគ្គ ក្នុងខណៈនៃមគ្គនោះ ។

**៤-បដិប្បស្សទ្ធិប្បហាន** ការលះកិលេសដាច់ខាតដោយលោកុត្តរមគ្គនោះហើយ កំពុងស្ថិតនៅក្នុងលោកុត្តរផល ។

៥-និស្សរណប្បហាន ការលះកិលេសដោយរលាស់ចេញអស់រលីង ក្នុងខណៈក្រោយលោកុត្តរផល ចូលដល់អមតធាតុ គឺ ព្រះនិព្វាន ។

បុថុជ្ជន[៤] កាត់កិលេសមិនដាច់ទេ លះបានត្រឹមតែ ២ ថ្នាក់ខាងដើម ព្រោះបញ្ញាមិនមុត មិនក្ដៅខ្លាំង ក្ដៅល្មមត្រឹមតែធ្វើកិលេសឲ្យទ្រោម និង ស្រាលស្ដើងខ្លះតែប៉ុណ្ណោះ ពេលក្រោយវាដុះឡើងវិញ ។ ចំណែកព្រះអរិយៈ កាត់កិលេសដាច់ខាត ព្រោះបញ្ញា (មគ្គញាណ) របស់លោកមុតណាស់ ក្ដៅខ្លាំងណាស់ កិលេសដាច់ឆេះក្រៀមអស់ទាំងឫសទាំងគល់ មិនអាចកើតឡើងវិញបានទេ ។

**លោកុត្តរមគ្គ**

លោកុត្តរមគ្គ កាត់កិលេសជាលំដាប់ដូចតទៅ -

---

[៤]- បុថុជ្ជន អ្នកក្រាស់ដោយកិលេស មាន ២ គឺ ១-កល្យាណបុថុជ្ជន បុថុជ្ជនល្អ កិលេសក្រាស់មែន តែចេះដឹងធម៌អាថ៌ខ្លះ ចេះស្ដាប់ហេតុផល ២-អន្ធបុថុជ្ជន បុថុជ្ជន ងងឹតងងល់ កិលេសក្រាស់ឃ្មឹក មិនដឹងធម៌អាថ៌ មិនស្ដាប់ហេតុផល យល់តាមតែគំនិតខ្លួន ។

១-ព្រះសោតា សោតាបត្តិមគ្គញ្ញាណ លះសំយោជនក្កិលេស បាន ៣ គឺ ១-សក្កាយទិដ្ឋិ ២-វិចិកិច្ឆា ៣-សីលព្វតបរាមាស និង លះអនុសយក្កិលេសបាន ២ គឺ ១-ទិដ្ឋានុស័យ ២-វិចិកិច្ឆានុស័យ ។

២-ព្រះសកិទាគាមី សកិទាគាមីមគ្គញ្ញាណ មិនបាន លះសំយោជនអ្វីបន្ថែមទៀតទេ គ្រាន់តែធ្វើរាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង និង ធ្វើកាមរាគានុស័យ និង បដិឃានុស័យ ឲ្យស្រាលស្តើង ។

៣-ព្រះអនាគាមី អនាគាមីមគ្គញ្ញាណ លះសំយោជនក្កិលេសបាន ២ គឺ ១-កាមរាគ ២-បដិឃ និង អនុសយក្កិលេសបាន ២ គឺ ១-កាមរាគានុស័យ ២-បដិឃានុស័យ ដាច់ស្រឡះ ។

៤-ព្រះអរហន្ត អរហត្តមគ្គញ្ញាណ លះសំយោជនក្កិលេសបាន ៥ គឺ ១-រូបរាគ ២-អរូបរាគ ៣-មាន ៤-ឧទ្ធច្ច ៥-អវិជ្ជា និងលះអនុសយក្កិលេសបាន ៣ គឺ ១-មានានុស័យ ២-ភវរាគានុស័យ ៣-អវិជ្ជានុស័យ

ដាច់ស្រឡះអស់ហើយ ឥតមានសេសសល់អ្វីឡើយ ។

## អធិដ្ឋាន ជាធម៌សំខាន់

ការសម្រេចចិត្តដាច់ខាត ឬ ការតាំងចិត្តឆ្ពោះដើម្បីឲ្យបានសម្រេចផលអ្វីមួយ ហៅថា អធិដ្ឋាន ។ អធិដ្ឋាន ជាបារមីធម៌១ ក្នុងចំណោមបារមីធម៌ទាំង១០ ។ អ្នកបដិបត្តិធម៌ ត្រូវតែមានអធិដ្ឋាន គឺការសម្រេចចិត្តដាច់ខាត ឧទាហរណ៍ អាត្មាអញ ត្រូវតែធ្វើសមាធិរាល់ថ្ងៃ ក្នុង១ថ្ងៃ ១៥នាទី ដូចនេះ ជាដើម ។ បើអធិដ្ឋានចិត្ត យ៉ាងណាហើយ គេត្រូវតែបដិបត្តិយ៉ាងនោះឲ្យបានទៀងទាត់ៗ ការបដិបត្តិដាច់ខាតទៀងទាត់នេះហើយ ដែលនាំឲ្យបានសម្រេចផល ។ ការធ្វើអ្វីដូចភ្លើងចំបើង ឬ ដូចពាក្យចាស់ថា "ទើកតាមខ្យល់ ខ្វល់តាមលោក" យកជាការមិនបានទេ ។ បើគោលការនោះធំ មានប្រយោជន៍ទូលំទូលាយ មានតម្លៃខ្ពង់ខ្ពស់ ត្រូវតែអធិដ្ឋានចិត្ត យកជីវិតជាដើមទុន ដូចជាព្រះពុទ្ធមានបុណ្យបានអធិដ្ឋានទៀបគល់ពោធិព្រឹក្សមុនបានត្រាស់ដឹងថា សាច់

ឈាម ចូររីងស្ងួតចុះ ជីវិត ចូរស្លាប់ចុះ បើមិនបានត្រាស់ដឹង អនុត្តរសម្មាសម្ពោធិញ្ញាណ អាត្មាអញនឹងមិនក្រោកចាក ទីនេះ ជាដាច់ខាត ។

យើងជាសិស្សរបស់ព្រះពុទ្ធ ត្រូវរៀនអធិដ្ឋានចិត្ត តាមបែបព្រះពុទ្ធ ។ អ្នកបដិបត្តិធម៌ កុំរវល់តែរើសគ្រូ រើសទីកន្លែង រើសគោលធម៌ ជ្រុលហួសពេក ត្រូវតែរើសខ្លួនឯង គឺអធិដ្ឋានចិត្ត ឲ្យច្បាស់លាស់ ។ អភិណ្ហបច្ចវេក្ខណធម៌ យកជាគោលបដិបត្តិបានហើយ ។ ទ្រឹស្តីព្រះត្រៃលក្ខណ៍ អនិច្ចំ ទុក្ខំ អនត្តា មានក្នុងអភិណ្ហបច្ចវេក្ខណៈនេះ ។ ទ្រឹស្តីកម្ម ផល ក៏មានក្នុងអភិណ្ហបច្ចវេក្ខណៈនេះដែរ ។ បដិបត្តិតាមព្រះពុទ្ធទៅ មគ្គនឹងកើតឡើង សំយោជនៈ ព្រមទាំងអនុស័យនឹងវិនាសអស់ទៅ ពិតពុំខាន ។

## អង្គរបស់អ្នកបានសម្រេចមគ្គផល ៦ យ៉ាង

| | |
|---|---|
| ១-សទ្ធា | ជំនឿល្អ |
| ២-ហិរិ | ខ្មាសបាប |
| ៣-ឱត្តប្ប | ខ្លាចបាប |

៤-វិរិយ ប្រឹងប្រែង

៥-បញ្ញា ឆ្លៀវឆ្លាត

៦-អនបេក្ខោ មិនអាឡោះអាល័យរូបកាយ និង ជីវិត គឺហ៊ានបូរជីវិត ។

កំណត់សំគាល់ : អ្នកបដិបត្តិធម៌ គប្បីចាប់អារម្មណ៍ គោលធម៌ទី ៦ នេះឲ្យមែនទែន ។

## ទឹកសេចក្ដីស្លាប់នាំឲ្យរវាន

អ្នកមិនបានសេពគប់សប្បុរស អ្នកមិនបានស្ដាប់ធម៌សប្បុរស ច្រើនតែមានគំនិតឆ្វេង ផុយពីសប្បុរស ផុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ គេច្រើននិយាយថា មិនបាច់គិតទេ ចាស់ ឈឺ ស្លាប់ វាមានមកជាធម្មតារបស់វាហើយ គិតគ្មានបានប្រយោជន៍អីទេ នាំឲ្យតែខាតពេល នាំឲ្យតែរវាន នរណាឧស្សាហ៍គិតដល់វា (ស្លាប់) មិនយូរទេវាមកដល់ឥឡូវហើយ ប្រយ័ត្ន ! កុំគិត កុំគិត កុំគិត ! ។

ក្នុងចំណោមពួកនេះ (មិនមែនទាំងអស់ទេ) អ្នកខ្លះគិតតែសប្បាយ ក្នុងផ្លូវអបាយមុខ ស្រី ស្រា ល្បែងពាលា

ផ្សេងៗ អ្នកខ្លះងប់ងល់នឹងស្វែងរកទ្រព្យសម្បត្តិក្លួចម៉ែឪ ក្លួចកូន ចៅ ជួនជាអកុសល មានគ្រោះថ្នាក់ ឬ សេចក្ដីស្លាប់មកដល់ ក៏យំសោកបោកខ្លួន មានហេតុដល់សម្លាប់ខ្លួនតាមទៅទៀតក៏មានដែរ ព្រោះតែមិនដែលបានស្ដាប់ធម៌របស់សប្បុរសសោះ ម៉្លោះហើយមិនដឹងបានអ្វីមកជួយទប់ទល់ទាំងបុណ្យកុសលក៏មិនសូវបានធ្វើ... មានតែទុក្ខក្រៀមក្រំនិង សេចក្ដីស្ដាយក្រោយ ។ អ្នកខ្លះ បុណ្យចាស់ជួយឧបត្ថម្ភមានអាយុវែងរស់រហូតដល់ចាស់ជរា តែមិនដឹងធម៌អាថ៌ មិនបានជួយជាតិ សាសនា អ្វីពិតប្រាកដទេ គិតតែដើរលេងសប្បាយ ឬ ដេកនឹកស្រមើស្រមៃដល់អតីតកាល... អញកូនឯកឧត្ដម អញមានសញ្ញាបត្រធំ អញមានសក្តិខ្ពង់ខ្ពស់... អស់ផុងទៅហើយនៅតែមិនដឹងខ្លួន ចូលវត្តម្ដងៗស្ពាយធំមកផង មិនចេះធ្វើខ្លួនឲ្យគេគោរពរាប់អាន មិនយូរប៉ុន្មានក៏ស្លាប់ទៅ ឥតសូវមានបុណ្យអ្វី ជាប់ទៅជាមួយខ្លួនប៉ុន្មានទេ ស៊ីតែបុណ្យចាស់ អត់ធ្វើបុណ្យថ្មី នេះហើយវាសនារបស់ពួកអ្នករំខាននឹងសេចក្ដីស្លាប់ ជោតិ គមមបរាយនោ អ្នកមកក្ដី

ទៅវិញងងឹត ។

## បុគ្គល ៤ ពួក

១-តមោ តមបរាយនោ អ្នកមកងងឹត ទៅវិញងងឹត។

២-តមោ ជោតិបរាយនោ អ្នកមកងងឹត ទៅវិញភ្លឺ ។

៣-ជោតិ តមបរាយនោ អ្នកមកភ្លឺ ទៅវិញងងឹត ។

៤-ជោតិ ជោតិបរាយនោ អ្នកមកភ្លឺ ទៅវិញភ្លឺ [៥] ។

## មរណស្សតិ ប្រសើរណាស់

ព្រះពុទ្ធ សម្តែងថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិ គឺ ការតាំងស្មារតីនឹកដល់សេចក្តីស្លាប់ ដែលគេចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌មានផលច្រើន មានអានិសង្សច្រើន ឈមទៅរកព្រះនិព្វាន មានព្រះនិព្វាន ជាទីបំផុត ។

ពុទ្ធដីកានេះ បញ្ជាក់ថា ការនឹកដល់សេចក្តីស្លាប់

---

(៥)- ងងឹត គឺ បាប, ភ្លឺ គឺ បុណ្យ ។ មកងងឹត គឺមកដោយផលបាប, មកភ្លឺ គឺមកដោយផលបុណ្យ ។ ទៅងងឹត គឺទៅដោយផលបាប ទៅភ្លឺ គឺ ទៅដោយផលបុណ្យ ។

មានប្រយោជន៍ច្រើន ហេតុបានសម្រេចព្រះនិព្វាន ។ ចុះហេតុអ្វីបានជាគេថា វាអត់ប្រយោជន៍... ? ព្រោះគេមិនចេះមិនចេះគិត ឬ គិតខុសទំនង ។ បើគេគិតដល់សេចក្តីស្លាប់របស់បុគ្គលជាទីស្រឡាញ់ គេនឹងកើតសេចក្តីសោក, បើគេគិតដល់សេចក្តីស្លាប់របស់ខ្លួនដោយប្រាសចាកបញ្ញា គេនឹងកើតសេចក្តីភ័យខ្លាច... ។ ដូចនេះ ការនឹកគិតដល់សេចក្តីស្លាប់ ត្រូវតែប្រកបដោយបញ្ញា គឺត្រូវដឹងថា ការកើតស្លាប់ជាច្បាប់ធម្មជាតិ មិនមែនជារឿងអ្វី គួរភ័យខ្លាច ឬ គួរឲ្យស្តាយស្រណោះទេ ប៉ុន្តែ វាជារឿង គួរឲ្យសង្វេគ គួរឲ្យក្រាក់រលឹក គេមិនគប្បីមានសេចក្តីប្រមាទ ត្រូវប្រញាប់ប្រញាល់ឈប់ធ្វើអំពើអាក្រក់ ហើយខំសន្សំសេចក្តីល្អ... ។ គិតយ៉ាងនេះ មានប្រយោជន៍ច្រើនណាស់ ។

បុគ្គលអ្នកមិននឹកគិតដល់សេចក្តីស្លាប់ ប្រៀបដូចអ្នកមិនបានចាក់ថ្នាំការពារ ហើយគិតតែដើរលេង ស៊ីផឹក... ។ ពេលមេរោគមកដល់ គ្មានអ្វីការពារ ទុក្ខលំបាក ឬ សេចក្តីស្លាប់មកដល់ គ្មានអ្វីទប់ទល់ គិតតែកើតទុក្ខក្រៀមក្រំ យំសោកស្តាយក្រោយ ។ ចំណែកបុគ្គលអ្នកនឹកដល់សេចក្តី

ស្លាប់ប្រៀបដូចអ្នកបានចាក់ថ្នាំការពារ អ្នកចេះថែរក្សាខ្លួន បានប្រើងប្រែងធ្វើការងារ និង ព្យាយាមជៀសវាង សេចក្ដីអាក្រក់ ហើយខំសន្សំសេចក្ដីល្អ...។ ពេលមេរោគមកដល់ មានគ្រឿងការពារ ទុក្ខលំបាកមកដល់ មានទ្រព្យជួយទប់ទល់ សេចក្ដីស្លាប់ជិតមកដល់ មានធម៌ជាឱសថជួយផ្សំ ព្រោះគេបានដឹង បានគិត បានប្រុងប្រៀបទុកហើយមិនទៀងៗ នេះជាច្បាប់ធម្មជាតិ ។ ហេតុនេះ អ្នកនឹកគិតដល់សេចក្ដីស្លាប់មានប្រយោជន៍ច្រើនណាស់ ។

ចំណែក ពាក្យដែលគេនិយាយថា អ្វីដែលយើងនឹកគិតរឿយៗវានឹងមកដល់យើង ឥឡូវហើយ បើគិតរឿងស្លាប់...ស្លាប់វាមករកយើង ។ ពិត ឬ ? សាកល្បងគិតចង់ធ្វើសេដ្ឋី ឬ នាយករដ្ឋមន្ត្រី តើវាមករកយើងទេ ? អត់មានសង្ឃឹមទេ បើមិនខំកសាងខ្លួន ។

ខ្ញុំ (អាត្មា) បាននឹកគិតដល់សេចក្ដីស្លាប់តាំងពីនៅក្មេងមុនបួស ព្រោះខ្ញុំបានចូលរៀនធម៌ជាមួយព្រះសង្ឃ ។ ខ្ញុំនឹកគិតសេចក្ដីស្លាប់ច្រើនរយពាន់ដងណាស់ រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែនឹកគិត នៅតែនិយាយ អ្នកខ្លះ

គេជុញគេថា មាត់ស៊ីអំបិល ប្រហុក កុំនិយាយ... ខ្ញុំថា ស៊ីទឹកត្រី ទឹកស៊ីអ៊ីវ ក៏ដូចតែគ្នា គ្មានអីទេ... ។ មិត្រខ្ញុំច្រើនណាស់ គេមិននឹករឿងនេះសោះ ប៉ុន្តែ គេស្លាប់ចោលខ្ញុំអស់ហើយ ខ្ញុំនៅតែនឹកសេចក្ដីស្លាប់រហូត ខំនិយាយឲ្យគេឮ គេបានយល់ខ្លះផង ប៉ុន្តែ ស្លាប់វាមិនទាន់មក ឥឡូវ ខ្ញុំអាយុជាង ៨០ ហើយ នៅទេសនា នៅសរសេរសៀវភៅនៅឡើយ បើឯងមក ខ្ញុំព្រមទៅជានិច្ច បើឯងមិនទាន់មក ខ្ញុំនៅធ្វើការសិន... ។ ដូចនេះ ការនឹកគិតដល់សេចក្ដីស្លាប់ប្រសើរណាស់ ដូចព្រះពុទ្ធដីកា នៃព្រះពុទ្ធជាម្ចាស់ ត្រាស់សម្ដែងទុកនោះមែន ។

## កម្ម អំពើ

អំពើដែលគេធ្វើដោយ កាយ វាចា ចិត្ត ហៅថា កម្ម។ អំពើដោយកាយ ហៅថា កាយកម្ម អំពើដោយវាចា ហៅថា វចីកម្ម អំពើដោយចិត្ត ហៅថា មនោកម្ម ។ អំពើល្អ ហៅថា កុសលកម្ម ឬ បុញ្ញកម្ម អំពើអាក្រក់ ហៅថា អកុសលកម្ម ឬ បាបកម្ម ។ កម្ម បើនិយាយឲ្យជ្រៅ សំដៅយកចេតនា គឺ

ការតាំងចិត្តធ្វើអំពើ ។ បើអំពើប្រកបដោយចេតនា ពេញលេញ មានផលច្រើន បើចេតនាមិនពេញលេញ មានផលមិនសូវច្រើនទេ ។

កម្មជាច្បាប់ធម្មជាតិ ជាច្បាប់ហេតុផល... ។ ច្បាប់ធម្មជាតិ ជាច្បាប់ទៀងទាត់ យុត្តិធម៌ មិនស្រឡាញ់ មិនស្អប់ មិននៅក្រោមបង្គាប់នរណា ឬ ព្រះអាទិទេពអង្គណាទេ ។ ភ្លើង ជាធម្មជាតិក្តៅ រលាក នរណា ប៉ះភ្លើង ក្តៅរលាក ។ នរណា ចេះប្រើភ្លើង នរនោះ បានប្រយោជន៍ នរណា មិនចេះប្រើភ្លើង នរនោះ ខូចប្រយោជន៍ ។ មិនមែនភ្លើងស្រឡាញ់ ឬ ស្អប់ទេ ភ្លើងឲ្យផលជាសច្ចធម៌ ទៀងទាត់យ៉ាងនេះ ជានិច្ច តាមច្បាប់ធម្មជាតិ ។ កម្ម ក៏ដូចគ្នានេះដែរ កម្ម គ្មានស្រឡាញ់ គ្មានស្អប់ មិននៅក្រោមបង្គាប់នរណាទេ កម្មឲ្យផលទៀងទាត់ជាដរាប ប៉ុន្តែ កម្ម មានលក្ខណៈប្លែកពីធម្មជាតិធម្មតា ត្រង់ដែលកម្មជាធម្មជាតិពិសេស មានចេតនាប្រកបផង ម៉្លោះហើយ វាធ្វើឲ្យមានការស្មុគស្មាញក្នុងការឲ្យផល កាន់តែច្រើនឡើងថែមទៀត តែប៉ុណ្ណោះ ។

**កម្មស្សកោម្ហិ** កម្មជារបស់ខ្លួន គឺជាប់តាមខ្លួនជានិច្ច គេទៅណា កម្មជាប់ទៅតាមដែរ ឯផ្ទះសម្បែងជាដើម មិនទៅតាមទេ ។ ចំណេះវិជ្ជា ជាប់តាមខ្លួនដែរ ប៉ុន្តែ បានត្រឹមតែមួយជាតិប៉ុណ្ណោះ ។ ឯកម្ម ជាប់តាមខ្លួនរហូតដល់ជាតិមុខតៗទៅទៀត ។ នេះ គឺពិតជារបស់ខ្លួនមែន ។ **កម្មទាយាទោ** ជាទាយាទនៃកម្ម គឺគេអ្នកធ្វើកម្ម គេត្រូវទទួលផលនៃកម្ម មិនមែនអ្នកធ្វើផ្សេង អ្នកទទួលផ្សេងទេ ។ **កម្មយោនិ** កម្មជាអ្នកបង្កើត គឺគេធ្វើស្រែ គេក៏ទៅជាអ្នកស្រែ គេលក់ដូរ គេក៏ទៅជាអ្នកជំនួញ គេធ្វើកិច្ចការរបស់ព្រះរាជា គេក៏ទៅជាអ្នករាជការ គេធ្វើតែអំពើល្អ គេក៏ទៅជាមនុស្សសុចរិត គេលួចប្លន់ ទ្រព្យសម្បត្តិអ្នកដទៃ គេក៏ទៅជាចោរ... ។ សូម្បីតែគេទៅកើតក្នុងជាតិមុខជា នរក ប្រេត មនុស្ស ឬ ទេវតា ក៏ដោយសារតែកម្មរបស់គេជាអ្នកបង្កើតទាំងអស់ ។ **កម្មពន្ធុ** កម្មជាផៅពង្ស គឺជាសាច់ញាតិ ។ ពេលមានធុរៈ (រវល់) ពួកញាតិ តែងមកជួយ ប៉ុន្តែ មិនបានគ្រប់ពេលទេ ។ ចំណែក កម្មដែលគេបានសន្សំហើយ ទុកជាញាតិយ៉ាងជិត

ស្និទ្ធ ឥតដែលខានទេ តែងតែមកជួយគេ គ្រប់ពេលវេលា ជាដរាប ។ កម្មប្បដិសរណោ មានកម្មជាទីពឹង គឺអ្នកដទៃក៏នៅតែទីពឹងដែរ ប៉ុន្តែ ទីពឹងដ៏សំខាន់បំផុតគឺ កម្មរបស់ខ្លួនហ្នឹងឯង បើគេមិនព្រមធ្វើអំពើល្អហើយ នរណា អាចធ្វើល្អជួសគេបាន នរណា ជាទីពឹងរបស់គេបាន ។ នរណាធ្វើនូវកម្មណា ល្អក្តី អាក្រក់ក្តី នរនោះ នឹងជាអ្នកទទួលនូវផលនៃកម្មនោះ ។

វដ្តៈ ធម៌ជាគ្រឿងវិលវង់ ៣ យ៉ាង

១-កិលេសវដ្តៈ ធម៌ជាគ្រឿងវិលវង់ គឺ កិលេសធម្មជាតធ្វើចិត្តឲ្យសៅហ្មង ។

២-កម្មវដ្តៈ ធម៌ជាគ្រឿងវិលវង់ គឺ កម្ម អំពើផ្សេងៗដែលបុគ្គលធ្វើ ។

៣-វិបាកវដ្តៈ ធម៌ជាគ្រឿងវិលវង់ គឺ វិបាក ផលដែលកើតអំពីកម្ម ។

និយាយតាម បដិច្ចសមុប្បាទ កិលេសវដ្តៈ បានដល់ អវិជ្ជា តណ្ហា ឧបាទាន ។ កម្មវដ្តៈ បានដល់ សង្ខារ ភព ។

វិបាកវដ្ដៈ បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

មនុស្សនៅមានកិលេស ធ្វើអំពើអ្វី ល្អក្តី អាក្រក់ក្តី ហៅថា កម្មទាំងអស់ ។ កម្មនោះ រមែងមានវិបាក គឺផល បន្តទៅទៀត ឧទាហរណ៍ ត្រូវទៅកើតជាមនុស្ស ឬ សត្វ... ជាដើម ដោយមានទាំងអនុសយក្កិលេសជាប់មកជាមួយ ផង ។ គេ ក៏ចាប់ធ្វើកម្មទៀត មានវិបាកទៀតរឿយៗ វិល ជាវង្វង់មូល រកទីបំផុតគ្មាន ។ ព្រះពុទ្ធអនន្តញាណ បរមគ្រូ របស់យើង ទ្រង់រកឃើញវិធីបញ្ចប់ការវិលវង់ នេះ ។

## កម្ម ៤ យ៉ាង

១-កម្មំ កណ្ហំ កណ្ហវិបាកំ កម្មខ្មៅឲ្យផលខ្មៅ។

២-កម្មំ សុក្កំ សុក្កវិបាកំ កម្មសឲ្យផលស ។

៣-កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ កម្មទាំងខ្មៅ ទាំងស ឲ្យផលទាំងខ្មៅទាំងស ។

៤-កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មមិន ខ្មៅមិនស ឲ្យផលមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។

កម្មខ្មៅ គឺ អកុសលកម្ម, ឲ្យផលខ្មៅ គឺជាទុក្ខ ឬ ទៅកើតក្នុងទុគ្គតិ ។ កម្ម ស គឺ កុសលកម្ម, ឲ្យផល ស គឺជាសុខ ឬ ទៅកើតក្នុងសុគតិ ។ កម្មទាំងខ្មៅទាំងស គឺ កម្មទាំងពីរនោះ លាយចម្រុះគ្នា, ឲ្យផលទាំងខ្មៅទាំងស ឧទាហរណ៍ ទៅកើតជាសត្វ ដែលមានគេយកទៅចិញ្ចឹមយ៉ាងល្អប្រពៃ ។ ឲ្យផលខ្មៅ គឺទៅកើតជាសត្វ ឲ្យផលស គឺ គេយកទៅចិញ្ចឹមយ៉ាងល្អប្រពៃ ។ កម្ម មិនខ្មៅមិនស ឲ្យផល មិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ យ៉ាងទាបសំដៅយក ចេតនាដើម្បីលះកម្មខ្មៅ ចេតនាដើម្បីលះកម្មស និង ចេតនាដើម្បីលះទាំងកម្មខ្មៅទាំងកម្មស របស់បុថុជ្ជន យ៉ាងខ្ពស់សំដៅយក ចតុមគ្គញ្ញាណរបស់ព្រះអរិយបុគ្គល ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើង ព្រះអង្គរកឃើញនូវកម្មប្រភេទទី ៤ នេះ គឺ វិធីបញ្ចប់សង្សារវដ្ដ ។

## កំណត់សំគាល់

១-សាសនាដទៃខ្លះ មានកម្មដែរ ប៉ុន្តែ គេមានព្រះអាទិទេព ជាអ្នកកសាង ជាអ្នកសម្រេច ឲ្យអ្នកនេះទៅកើត

ជាព្រាហ្មណ៍ ជាក្សត្រ ឲ្យអ្នកនោះទៅកើតជាវេស្សៈ សូទ្រៈ ឲ្យអ្នកនេះទៅកើតក្នុងឋានសួគ៌ ឲ្យអ្នកនោះទៅកើតក្នុងអបាយ គេជាម្ចាស់ មានតួនាទីធំជាងកម្មទៅទៀត ។

២-សាសនាខ្លះទៀត មានកម្មដែរ មិនមានព្រះ-អាទិទេពទេ ប៉ុន្តែ គេឲ្យតម្លៃទៅលើកម្មចាស់ទាំងអស់ អ្វីៗសុទ្ធតែកម្មចាស់ ពីអតីតៈកំណត់ ឬ សម្រេចឲ្យទាំងអស់ហាក់ដូចជាបដិសេធកម្មបច្ចុប្បន្នចោល ។

៣-ចំណែក ពុទ្ធសាសនា មានកម្មដែរ មិនមានព្រះ-អាទិទេពទេ ប៉ុន្តែ មិនឲ្យតម្លៃទៅលើតែកម្មចាស់ទាំងអស់ទេ ត្រូវបូកកម្មថ្មីផ្សំចូលគ្នាទើបឲ្យតម្លៃ ហើយកម្មថ្មីនេះ មានតួនាទីសំខាន់ណាស់ ។ ពិសេសជាងនេះទៅទៀត ពុទ្ធ-សាសនា មានវិធីធ្វើឲ្យអស់កម្ម ដើម្បីបានសម្រេចព្រះនិព្វាន ។ អ្នកចង់សម្រេចព្រះនិព្វាន ត្រូវចាប់អារម្មណ៍ ត្រូវសិក្សា ត្រូវបដិបត្តិ រៀនអស់កម្មនេះ ។

## បុញ្ញកិរិយាវត្ថុ

បុញ្ញកិរិយាវត្ថុ ប្រែថា ទីតាំងនៃការធ្វើបុណ្យ ឬ គោល

ការសំរាប់បង្កើតបុណ្យ ។ បុណ្យមិនមែនកើតឡើងឯងទេ លុះណាតែគេធ្វើ ទើបវាកើត ។ បើគេធ្វើខុសទីតាំងរបស់វា បុណ្យវាមិនកើតទេ ឯរបស់ដែលកើតពីការធ្វើខុសទីតាំងនោះ មិនមែនជាបុណ្យទេ ។ សូម្បីគេធ្វើត្រូវទីតាំងរបស់វាហើយ ប៉ុន្តែ គេធ្វើខុសទំនង ដូចឲ្យគ្រឿងញៀនជាដើម ក៏មិនរាប់ថា ជាបុណ្យដែរ ។ ដូចនេះ អ្នកចង់បានបុណ្យ ត្រូវសិក្សាឲ្យ ចេះរៀងបុណ្យល្អមប្រើការបាន ហើយធ្វើឲ្យត្រូវទីតាំងរបស់ វា ទើបកើតបុណ្យ ។

## បុញ្ញកិរិយាវត្ថុ

### ទីតាំងនៃការធ្វើបុណ្យ ៣ យ៉ាង

១-ទានមយៈ បុណ្យកើតដោយសារការធ្វើទាន ។

២-សីលមយៈ បុណ្យកើតដោយសារការរក្សាសីល ។

៣-ភាវនាមយៈ បុណ្យកើតដោយសារការចំរើនភាវនា ។

**ទានមយៈ** បុណ្យកើតដោយសារការធ្វើទាន ។ ធ្វើ ទានគឺការចែករំលែកទ្រព្យជាអំណោយ ដើម្បីជួយសង្គ្រោះ ដល់អ្នកខ្វះខាត, ដើម្បីបូជាគុណចំពោះ លោក អ្នក មានគុណ

បការៈ ឬ មានគុណធម៌ច្រើន, និង ដើម្បីលះសេចក្តីកំណាញ់ ឬ ការជាប់ជំពាក់ចិត្ត ។ ព្រះពុទ្ធបរមគ្រូយើងព្រះអង្គ សាងទានបារមី ច្រើនណាស់ ព្រះអង្គត្រាស់សំដែងថា បើគេយល់នូវផលនៃការធ្វើទាន ដូចជាព្រះអង្គយល់សូម្បីមានបាយត្រឹមតែ ១ ពំនូត ក៏គេធ្វើទានពាក់កណ្តាលដែរបើមានអ្នកត្រូវការ ។ យើងបានមកកើតជាមនុស្សដោយ-សារបុណ្យ កើតជាមនុស្សហើយ មិនចេះធ្វើបុណ្យធ្វើទានមិនមែនជាមនុស្សល្អទេ ។ ការធ្វើទាន ជាសេចក្តីល្អមែនប៉ុន្តែ គេត្រូវតែពិចារណា បើគេមិនពិចារណាឲ្យត្រឹមត្រូវអាចចាញ់បោកគេក៏បាន ។ ព្រះពុទ្ធ ទ្រង់ញាណ សម្តែងទុកថា **វិចេយ្យទានំ ទាតព្វំ ស្វគតប្បសត្ថំ** ធ្វើទានត្រូវពិចារណា ពិចារណាល្អហើយ ព្រះសុគត ទ្រង់សរសើរ ។ ធ្វើទាន កំចាត់បង់នូវ លោភៈ, ធ្វើទាន នាំឲ្យបានភោគសម្បត្តិ។

**សីលមយៈ** បុណ្យកើតដោយសារការរក្សាសីល ។ រក្សាសីល គឺរក្សាកាយ វាចា ឬ កាយកម្ម វចីកម្ម ឲ្យរៀបរយ កុំឲ្យប៉ះពារទៅលើបុគ្គលដទៃ ។ រក្សាកាយកម្ម វចីកម្ម

បានល្អ ត្រូវតែរក្សាចិត្ត គឺតាំងចេតនាវៀរចាកតាមសិក្ខាបទនោះៗ បើគេមិនរក្សាចិត្តទេ គ្មានអ្វីទៅរក្សា កាយកម្ម វចីកម្ម បានទេ ។ សីល យ៉ាងតិច មាន ៥ ប្រការ គឺៈ ១-វៀរចាកការសម្លាប់សត្វ ២-វៀរចាកការយកទ្រព្យដែលគេមិនបានឲ្យ ៣-វៀរចាកការប្រព្រឹត្តខុសក្នុងកាម គឺ ប្ដីប្រពន្ធ កូន អ្នកដទៃ ៤-វៀរចាក ការនិយាយមិនពិត ៥-វៀរចាកការផឹកសុរា មេរ័យ (គ្រឿងស្រវឹង) ។ បុគ្គលកាន់ត្រឹម សីល ៥ នេះ មិនទាន់បាន មិនទាន់រាប់ ថាជាអ្នកល្អ បានទេ ។ សីល ជាគុណជាតិដ៏ល្អ សីលជាគ្រឹះ សីលជាមេបុណ្យ ។ អ្នកធ្វើទាន បើមិនរក្សាសីលផង មិនសូវបានបុណ្យច្រើនទេៗ អ្នកចំរើនភាវនា បើមិនរក្សាសីលផង ភាវនាកើតមិនបានល្អ ទេ ។ ដូចនេះ គេត្រូវតែនាំគ្នារក្សាសីល ។ រក្សាសីល កំចាត់បង់នូវទោសៈ រក្សាសីល នាំឲ្យបានរូបសម្បត្តិ ។

**ភាវនាមយៈ** បុណ្យកើតដោយសារការចំរើនភាវនាៗ ភាវនា គឺការអប់រំចិត្ត ឬ ការអភិវឌ្ឍន៍ កាយ វាចា ចិត្ត ។

ចិត្ត ជាអ្នកដឹកនាំ កាយ និង វាចា បើចិត្តអាក្រក់ កាយ វាចា ក៏អាក្រក់ បើចិត្តល្អ កាយ វាចា ក៏ល្អ ។ ចិត្តដែលគេមិនបានអប់រំ ឲ្យទោសច្រើនជាង ពួកចោរខ្មាំង ឬ ពួកអ្នកចងពៀរគ្នាទៅទៀត ។ ចិត្តដែលគេបានអប់រំល្អហើយ ឲ្យគុណច្រើនជាង មាតាបិតា និង ពួកញាតិឲ្យទៅទៀត ។ ភាវនា ជាមធ្យោបាយរំលត់ទុក្ខ មានប្រសិទ្ធភាពល្អជាងគេបំផុត ភាវនា ជាផ្លូវតែមួយនាំទៅរកព្រះនិព្វាន វៀរចាកភាវនាហើយ មិនអាចសម្រេចព្រះនិព្វាន បានទេ ភាវនា ជាមេបុណ្យបានផលច្រើនជាងគេទាំងអស់ ។ ហេតុនេះ គេត្រូវតែនាំគ្នាចំរើន ភាវនា ។ ភាវនា កំចាត់បង់នូវ មោហៈ ភាវនា នាំឲ្យបាន គុណសម្បត្តិ ៕

ហេតុនេះ នរណាចង់បាន រូបសម្បត្តិ ភោគសម្បត្តិ និង គុណសម្បត្តិ នរនោះ ត្រូវបដិបត្តិ បុញ្ញកិរិយាវត្ថុនេះ ។

## ចិត្តំ ទន្តំ សុខាវហំ

ចិត្ត ដែលគេទូន្មានហើយ នាំមកនូវសេចក្ដីសុខ ។

## ភាវនា ២ យ៉ាង

១-សមថភាវនា ការអប់រំចិត្តឲ្យស្ងប់ ។

២-វិបស្សនាភាវនា ការអប់រំចិត្តឲ្យមានបញ្ញា ។

*សភាពរបស់ចិត្ត* : ចិត្តជាធម្មជាតដឹងអារម្មណ៍ ជាធម្មជាតទទួលអារម្មណ៍ជានិច្ច ។ ពេលទទួលអារម្មណ៍ល្អ ចិត្តសប្បាយ, ពេលទទួលអារម្មណ៍អាក្រក់ ចិត្តកើតទុក្ខ, ពេលទទួលអារម្មណ៍មិនល្អ មិនអាក្រក់ ចិត្តកណ្ដាលៗ គឺ មិនសប្បាយ មិនកើតទុក្ខ ។ នេះ ជាធម្មតា របស់ចិត្ត ។

ចិត្តជាធម្មជាតអប់រំបាន ។ បើគេមិនអប់រំវា វាឲ្យផលធម្មតាៗប៉ុណ្ណឹង គឺម្ដងសើច ម្ដងយំ... តាំងពីព្រឹក ទល់ល្ងាច មិនមានអ្វីប្លែកពីសត្វប៉ុន្មាន យូរៗទៅ ក្លាយជាសត្វហើយ ។ បើគេអប់រំវា វាជួយបំបាត់ទុក្ខចំរើនសុខ ជួយឲ្យបានផលប្រយោជន៍ច្រើនឡើង ខ្ពស់ឡើងៗទៅជាទេវតា ឥន្ទ ព្រហ្ម រហូតបានសម្រេចព្រះនិព្វាន ។ ដូចនេះ គេត្រូវតែរៀនអប់រំចិត្ត ។

## ទ្វារទទួលអារម្មណ៍ មាន ៦ យ៉ាង

១-ចក្ខុទ្វារ ទ្វារភ្នែក

២-សោតទ្វារ ទ្វារត្រចៀក

៣-ឃានទ្វារ ទ្វារច្រមុះ

៤-ជីវ្ហាទ្វារ ទ្វារអណ្តាត

៥-កាយទ្វារ ទ្វារកាយ

៦-មនោទ្វារ ទ្វារចិត្ត ។

### អារម្មណ៍មាន ៦ យ៉ាង

១-រូបារម្មណ៍ អារម្មណ៍ជារូប ។

២-សទ្ទារម្មណ៍ អារម្មណ៍ជាសម្លេង ។

៣-គន្ធារម្មណ៍ អារម្មណ៍ជាក្លិន ។

៤-រសារម្មណ៍ អារម្មណ៍ជារស ។

៥-ផោដ្ឋព្វារម្មណ៍ អារម្មណ៍ជាផោដ្ឋព្វៈ (អ្វីដែលប៉ះកាយ) ។

៦-ធម្មារម្មណ៍ អារម្មណ៍ជាធម៌ (អ្វីដែលប៉ះចិត្ត) ។

## សមថភាវនា ការអប់រំចិត្តឲ្យស្ងប់ ។

តាមធម្មតា ចិត្តមិនសូវបានស្ងប់ទេ ព្រោះមានអារម្មណ៍ជាច្រើនគឺ រូប សម្លេង... ជាដើម ចូលមកតាមទ្វារទាំងឡាយ មានទ្វារភ្នែកជាដើមរឿយៗ ម៉្លោះហើយវាធ្វើឲ្យចិត្តមានរវល់ច្រើន នឿយហត់ច្រើនក្នុងការទទួលអារម្មណ៍ទាំងនោះ ។ ដូចនេះ ដើម្បីធ្វើឲ្យចិត្តស្ងប់ ឲ្យចិត្តមានកម្លាំងពលំ មានសមត្ថភាពច្រើន គេត្រូវរកឧបាយអប់រំចិត្ត ជាឧទាហរណ៍គឺ ក-ត្រូវរកទីកន្លែងសមរម្យ អង្គុយឲ្យបានស៊ប់ស្រួល ខ-ត្រូវបិទទ្វារទទួលអារម្មណ៍ទាំង ៥ ខាងដើមទុកតែមនោទ្វារ១ គ-តាមមនោទ្វារនោះ មានអារម្មណ៍ច្រើនណាស់ ត្រូវបិទអារម្មណ៍នោះទៀត ហើយជ្រើសរើសយកអារម្មណ៍ជាកុសលណាមួយ ដូចជា អានាបានស្សតិ ការតាំងសតិចាំមើលដង្ហើមចូលចេញ ធ្វើជាគោលសំរាប់អប់រំចិត្ត ឃ-កាលបានអារម្មណ៍ជាកុសលនោះហើយ គេត្រូវយកសតិចាំមើលដង្ហើមចូល ចេញនោះ គឺគេត្រូវមានសតិ ដកដង្ហើមចូល គេត្រូវមានសតិដកដង្ហើមចេញ ។

ការត្រៀម មុនដំបូងត្រឹមប៉ុណ្ណឹង ។ បន្ទាប់មក

១-កាលដកដង្ហើមចូលវែង គេដឹងច្បាស់ថា ដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញវែង គេដឹងច្បាស់ ថា ដកដង្ហើមចេញវែង ។

២-កាលដកដង្ហើមចូលខ្លី គេដឹងច្បាស់ថា ដកដង្ហើមចូលខ្លី ។ កាលដកដង្ហើមចេញខ្លី គេដឹងច្បាស់ថា ដកដង្ហើមចេញខ្លី ។

៣-គេសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល ។ គេសិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ ។

៤-គេសិក្សាថា អាត្មាអញ នឹងរម្ងាប់នូវកាយសង្ខារ គឺខ្យល់ចូល-ចេញ ហើយដកដង្ហើមចូល ។ គេសិក្សាថា អាត្មាអញ នឹងរម្ងាប់នូវកាយសង្ខារ គឺខ្យល់ចូល-ចេញ ហើយដកដង្ហើមចេញ ។ ។ល។

កាលបើគេបដិបត្តិតាមនេះ ហើយចិត្តរបស់គេមូលនៅក្នុងអារម្មណ៍តែមួយ គឺខ្យល់ដង្ហើមចូល-ចេញនោះ

ឈ្មោះថា ចិត្តរបស់គេបាប់ស្ងប់ហើយ ។ សូមខំបដិបត្តិឲ្យបានច្រើនឡើងៗជាលំដាប់តទៅទៀតចុះ ។ បានធម៌ហើយ ។

---

ពីអតីតកាល មិនទាន់មាន វិបស្សនាភាវនា, អ្នកចំរើនសមាធិ គេចំរើនសមាធិច្រើនឡើងៗ រហូតបានសម្រេចរូបឈាន ៤ អរូបឈាន ៤ គេបានសេចក្តីស្ងប់ បានសេចក្តីសុខគួរសមដែរ តែគេមិនអាចសម្រេចព្រះនិព្វានបានទេ គឺបានត្រឹមតែសម្រេចឈានប៉ុណ្ណោះ ។

លុះដល់ពុទ្ធកាល ព្រះពុទ្ធបរមគ្រូយើង រកឃើញវិបស្សនាភាវនា ជាវិធីបដិបត្តិ ធ្វើឲ្យសម្រេចព្រះនិព្វានបាន។ អ្នកបដិបត្តិមួយចំនួនធំ ធ្វើសមាធិតែល្មមៗ មិនចាំបាច់ដល់សម្រេចឈានទេ ងាកមកចំរើនវិបស្សនាភាវនាវិញ ព្រោះឆាប់បានសម្រេចព្រះនិព្វានជាង ប៉ុន្តែ ព្រះពុទ្ធ ក៏នៅតែត្រូវការឈានសមាបត្តិ ដដែល ឥតមានបោះបង់ចោលទេ ។

សម័យសព្វថ្ងៃនេះ មិនឃើញមានអ្នកចំរើនសមាធិដល់ថ្នាក់ឈានសមាបត្តិទេ គេចំរើនសមថភាវនា ល្មមសមគួរហើយ ចាប់ចំរើនវិបស្សនាភាវនា បន្តទៅទៀតតែម្តង ៕

**ទិបស្សនាភាវនា** ការអប់រំចិត្តឲ្យមានបញ្ញា ។

បញ្ញាមាន ២ យ៉ាង គឺ :

១-បញ្ញាផ្លូវលោក ចេះដឹង ឆ្លៀវឆ្លាតក្នុងវិជ្ជាផ្សេងៗ សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិត ។

២-បញ្ញាផ្លូវធម៌ ចេះដឹងឃើញច្បាស់តាមសេចក្ដីពិត នូវសភាវធម៌ទាំងឡាយមានមនុស្សជាដើម តើសេចក្ដីពិតវាយ៉ាងម៉េចមានពិតមែនឬទេ?។ ការអប់រំចិត្តឲ្យមានបញ្ញាមិនមែនយកបញ្ញាផ្លូវលោកទេ សំដៅយកបញ្ញាផ្លូវធម៌នេះឯង។

សូមពិចារណាមើល សភាវធម៌មួយ ដែលគេហៅថាមនុស្ស តើត្រង់ណាទៅហៅថាមនុស្ស ? គ្មានកន្លែងត្រង់ណាមួយហៅថាមនុស្សទេ គេឃើញមានតែក្បាល ខ្លួន ដៃជើង ឬមាន សក់ រោម ក្រចក ធ្មេញ ស្បែក ឬក៏មានតែធាតុ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ប៉ុណ្ណោះ គ្មានត្រង់ណាមួយហៅថា មនុស្សទេ ប៉ុន្តែ កាលណាវារួមបូលគ្នា មានលក្ខណៈយ៉ាងនេះ គេហៅថា មនុស្ស ។ ដូច្នេះ មនុស្សជាការសន្មត ឬ បញ្ញត្តិ ។

ទំនងដូចគ្នានេះដែរ រទេះ គ្មានកន្លែងត្រង់ណាមួយហៅថា រទេះ ទេ ឃើញមានតែ កង់ ប្រែកត្រង់ ប្រែក ង ទ្រុង ទូក ចន្ទោល ជាដើម ប៉ុន្តែកាលណារាប់រួមចូលគ្នា មានលក្ខណៈយ៉ាងនេះ គេហៅថា រទេះ ។ ដូចនេះ រទេះ ជាការសន្មត ឬ បញ្ញត្តិ ។ នេះ ជាសេចក្តីពិតនៃសការជធម៌ ។

ព្រះពុទ្ធ សម្តែងថា មនុស្សគឺខន្ធ៥ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមានអ្វីលើសពីនេះទៀតទេ ដូចនេះ គ្មានកន្លែងត្រង់ណាមួយហៅថា មនុស្សទេ ។ មនុស្ស ជាការសន្មត ឬ បញ្ញត្តិ ។

ខន្ធ ៥ បំព្រួញឲ្យខ្លីមាន ២ គឺ រូប និង នាម ។ រូប ចាត់ជារូប, វេទនា សញ្ញា សង្ខារ វិញ្ញាណ ចាត់ជានាម ។ ខន្ធ ៥ ត្រូវប្រព្រឹត្តទៅតាមច្បាប់ព្រះត្រៃលក្ខណ៍ គឺ អនិច្ចំ មិនទៀង ទុក្ខំ ជាទុក្ខ អនត្តា មិនមែនខ្លួន[៧] (បង្គាប់បញ្ជា-

---

[៧]–មិនមែនខ្លួនព្រោះមិនមានអ្វីជារបស់គេសោះទេ រូបបានមកពីមាតាបិតាចែកឲ្យ សាច់ ឈាម បានមកពីបាយទឹកនំចំណី ត្រី សាច់ ជាដើម ។ តើត្រង់ណាទៅជាខ្លួនជារបស់ខ្លួន ? គ្មានត្រង់ណាជាខ្លួន ជារបស់ខ្លួនទេ ព្រោះទាមទារមិនបាន បង្គាប់បញ្ជាមិន-បាន យកទៅមិនបាន ។ ដែលគេអាចរាប់ថាជារបស់ខ្លួនបាន គឺ កម្មតែប៉ុណ្ណោះ ។

មិនបាន) ។

បើខន្ធ៥វាមានលក្ខណៈ ៣ យ៉ាងនេះ តើក្នុងអ្វីដែលគេហៅថា មនុស្សនោះ មានអញទេ មានឯងឬទេ ? មិនមានទេ ។ បើមិនមានអញ តើមានរបស់អញមកពីណា ? គេមិនគួរនាំគ្នាយល់ខុសតទៅទៀតទេ ។ បុគ្គលគប្បីយល់ឃើញ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះ មិនមែនរបស់អញ អញ មិនមែនជានុ៎ះ នុ៎ះ មិនមែនជាខ្លួនរបស់អញ ។ យល់យ៉ាងនេះ ទើបផុតទុក្ខ ។

ដោយខ្វះ វិបស្សនាបញ្ញា ធ្វើឲ្យមនុស្សយើងយល់ខុស កើតកិលេស តណ្ហា មានៈ ទិដ្ឋិ បង្កសេចក្តីទុក្ខដល់ខ្លួនឯង ដល់អ្នកដទៃ និង ដល់សង្គម រៀបមិនចប់ រាប់មិនអស់ ។ ព្រោះហេតុដូចនោះ យើងត្រូវនាំគ្នាបណ្តុះ (ចំរើន) វិបស្សនាបញ្ញា ឲ្យច្រើនឡើងៗ ដើម្បីយើងបានយល់ត្រូវ ទើបយើងអាចរំលត់ទុក្ខ បានទទួលសេចក្តីសុខក្សេមក្សាន្ត រហូតបានសម្រេច ព្រះនិព្វាន ជាបរិយោសាន ។

## ភាវនា ៤ យ៉ាង

១-កាយភាវនា ការអប់រំកាយ

២-សីលភាវនា ការអប់រំសីល

៣-ចិត្តភាវនា ការអប់រំចិត្ត

៤-បញ្ញាភាវនា ការអប់រំបញ្ញា ។

*កាយភាវនា* ការអប់រំកាយ គឺការអប់រំឲ្យចេះដើរ ឈរ អង្គុយ ដេក ចេះទុកដាក់ខ្លួនឲ្យមានអាកប្បកិរិយា ឫកពា សុភាព រៀបរយ ចេះប្រើ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ឲ្យកើតប្រយោជន៍ច្រើន ចេះថែរក្សាខ្លួន និង ស្លៀកពាក់ឲ្យសមរម្យ ចេះរៀបចំទុកដាក់របស់ប្រើប្រាស់ ឲ្យមានរបៀប សណ្តាប់ធ្នាប់ល្អ ។

*សីលភាវនា* ការអប់រំសីល គឺការអប់រំឲ្យចេះ រក្សាសីល មានសីល៥ជាដើម សង្រួមឲ្យសមតាមភូមិភេទ របស់ខ្លួន និយាយរួម គឺ ប្រកបព្រមដោយ សម្មាកម្មន្តៈ សម្មាវាចា និង សម្មាអាជីវៈ ។

*ចិត្តភាវនា* ការអប់រំចិត្ត គឺការអប់រំចិត្ត ឲ្យចេះស្រឡាញ់ប្រយោជន៍រួម ឲ្យមានយុត្តិធម៌ ឲ្យមានមេត្តាករុណា ឲ្យចេះអត់ធន់ តស៊ូប្រឹងប្រែង... និង អប់រំចិត្តឲ្យស្ងប់រម្ងាប់ និយាយរួម គឺ ប្រកបព្រមដោយ សម្មាវាយាមៈ សម្មាសតិ និង សម្មាសមាធិ ។

*បញ្ញាភាវនា* ការអប់រំបញ្ញា គឺការអប់រំចិត្ត ឲ្យមានបញ្ញា ស្គាល់ បាប បុណ្យ គុណ ទោស ខុស ត្រូវ ខាតចំណេញ ប្រយោជន៍ មិនមែនប្រយោជន៍ និង អប់រំចិត្តឲ្យមានបញ្ញា ឃើញច្បាស់នូវសភាវធម៌ តាមសេចក្ដីពិតនិយាយរួម គឺ ប្រកបព្រមដោយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ ។

ភាវនា ៤ យ៉ាងនេះ គឺធម៌ជាមួយគ្នា ផ្លូវជាមួយគ្នាទៅជាមួយគ្នា ដល់ទីបំផុតជាមួយគ្នានឹង ភាវនា ២ យ៉ាង គឺ ៣ ខាងដើម ចាត់ជាសមថភាវនា ១ ខាងចុង ចាត់ជាវិបស្សនាភាវនា ។ សូម លោក អ្នក សិក្សា បដិបត្តិភាវនានេះ ឲ្យបានសម្រេចប្រយោជន៍ យ៉ាងល្អប្រពៃចុះ ។

# រោហិតស្សសូត្រ

ព្រះមានព្រះភាគ គង់នៅវត្តជេតពន... ក្រុងសាវត្ថី ។ រោហិតស្សទេវបុត្រ ចូលទៅក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ដល់ទីប្រថាប់ ហើយក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងលោកណា ទីបំផុតលោកនោះ បុគ្គលអាចដើម្បីដឹង ដើម្បីឃើញ ឬ ដើម្បីដល់ ដោយការទៅដោយជើងបានដែរឬ ?

ព្រះពុទ្ធ ត្រាស់ថា ម្នាលអាវុសោ តថាគត មិនពោលថា ទីបំផុតលោក ដែលសត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការទៅដោយជើងទេ ។

រោហិតស្សទេវបុត្រ ពោលថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ មិនធ្លាប់មានទេ ព្រោះព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគ ទ្រង់ពោលហើយដោយប្រពៃថា ម្នាល-

អាវុសោ តថាគត មិនពោលថា ទីបំផុតលោក ដែលសត្វ មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការទៅដោយជើងទេ ។

បពិត្រព្រះអង្គដ៏ចំរើន កាលពីព្រេងនាយ ខ្ញុំព្រះអង្គបានកើត ជាឥសី ឈ្មោះរោហិតស្ស ជាកូននៃឥស្សរជន មានឫទ្ធិហោះទៅក្នុងអាកាសបាន ។ ខ្ញុំព្រះអង្គនោះ មានសន្ទុះដូចអាចារ្យអ្នកបង្រៀនសិល្បធ្នូ ចាប់ធ្នូមាំ បានសិក្សាល្អហើយ មានដៃស្ទាត់ ជំនាញក្នុងការសិក្សា ធ្លាប់ចូលប្រឡងប្រជែងបាញ់ធ្នូ អាចយកព្រួញដែលស្រាលបាញ់កាត់ទទឹងស្រមោលដើមត្នោត ដោយមិនលំបាកសោះឡើយ ។

បពិត្រព្រះអង្គដ៏ចំរើន ជំហាននៃខ្ញុំព្រះអង្គនោះ មានសភាពដូចជាឈានអំពីសមុទ្រខាងកើត ទៅកាន់សមុទ្រខាងលិច ។ ខ្ញុំព្រះអង្គ មានប្រាថ្នាយ៉ាងនេះថា អាត្មាអញនឹងដល់ទីបំផុតលោកដោយថ្មើរជើង ។ ខ្ញុំព្រះអង្គមានសន្ទុះយ៉ាងនេះ មានជំហានយ៉ាងនេះ វៀរលែងតែវេលាស៊ី ទំពាស៊ី

និង គ្រប់ជញ្ជក់ វៀរលែងតែការបន្ទោបង់ឧច្ចារៈ បស្សាវៈ វៀរលែងតែការដេកលក់ និង ការបន្ទោបង់ នូវសេចក្ដីនឿយហត់ មានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ ធ្វើដំណើរទៅអស់១០០ ឆ្នាំ មិនបានដល់ទីបំផុត លោកសោះ ហើយក៏ធ្វើមរណកាលក្នុងរវាងនោះ ។ បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ មិនធ្លាប់មានទេ ព្រោះ ព្រះពុទ្ធ-ដីកានេះ ព្រះមានព្រះភាគ ទ្រង់ពោលហើយដោយប្រពៃថា ម្នាលអាវុសោ តថាគត មិនពោលថា ទីបំផុតលោក ដែលសត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការទៅដោយជើងទេ ។

ព្រះពុទ្ធ ត្រាស់ថា ម្នាលអាវុសោ តថាគត មិនពោលថា ទីបំផុតលោក ដែលសត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការទៅដោយជើងទេ ម្នាលអាវុសោ មួយទៀត តថាគត មិនពោលថា បុគ្គលមិនដល់ទីបំផុតលោក ហើយ

ធ្វើទីបំផុតទុក្ខបានទេ ម្នាលអាវុសោ ប៉ុន្តែ តថាគត បញ្ញត្ត នូវលោក នូវហេតុកើតឡើងនៃលោក នូវការរលត់នៃលោក នូវបដិបទា ជាហេតុដល់ការរំលត់នៃលោក ក្នុងរាងកាយប្រមាណមួយព្យាម ដែលប្រកបដោយសញ្ញា ប្រកបដោយចិត្តនេះឯង ។

ទោះបីក្នុងកាលណាក៏ដោយចុះ
មិនដែលមានមនុស្សឬសត្វណាដល់
ទីបំផុតលោកដែលអស់កន្លង់
ដោយហោះទៅដល់ឬដោយធ្វើរជើង ។
មិនទាន់ដល់ទីបំផុតលោកសោះ
កុំអាលលោតផ្លោះថាអស់ពួកយើង
រួចផុតចាកទុក្ខបានសុខថ្កុំថ្កើង
ជាការស្រមើងស្រមៃទេណា ។
អ្នកដឹង អ្នកឃើញ ឬ អ្នកទៅដល់
លោកអស់កន្លល់អ្នកមានបញ្ញា

ឃើញច្បាស់នូវលោក ហើយអស់សង្កា
លែងមានប្រាថ្នាលោកអ្វីទៀតហើយ[៨] ។

## រឿង សុប្បពុទ្ធសក្កៈ

ព្រះបរមសាស្តា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធ ព្រះអង្គម្ចាស់សក្យៈ ព្រះនាម សុប្បពុទ្ធ ត្រាស់សម្តែងធម្មទេសនានេះថា ៖ **ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ** ជាដើម ។

ដូចបានឮមកថា ព្រះបាទសុប្បពុទ្ធ អង្គនេះ បានចងគំនុំ នឹងព្រះសម្មាសម្ពុទ្ធ ដោយហេតុ ២ ប្រការគឺៈ ១-ព្រះពុទ្ធបានរត់ទៅបួសចោលព្រះនាងពិម្ពា កូនស្រីរបស់ខ្លួនឲ្យនៅមេម៉ាយ ២-ព្រះពុទ្ធ បានបំបួសទេវទត្តកូនប្រុសរបស់ខ្លួន

---

[៨]- សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ ២៩-២៩៩-១៦៦

ធ្វើឲ្យមានកម្មពៀរវេរាក្នុងគ្នាថែមទៀត ។

ថ្ងៃមួយ ព្រះបាទសុប្បពុទ្ធ គិតបិទផ្លូវមិនឲ្យព្រះពុទ្ធ និមន្តទៅទទួលភត្តាហារតាមទីដែលគេនិមន្ត ហើយស្តេចទៅគង់សោយសុរានៅចំកណ្តាលផ្លូវ ។

លំដាប់នោះ កាលព្រះសាស្តា មានភិក្ខុសង្ឃចោមរោម ជាបរិវារ ស្តេចនិមន្តដល់ទីនោះ អមាត្យ ក្រាបទូលព្រះបាទសុប្បពុទ្ធថា ព្រះសាស្តាស្តេចនិមន្តដល់ហើយ ។ ព្រះបាទសុប្បពុទ្ធ ត្រាស់ថា សមណគោតម មិនមែនធំជាងយើងទេ យើងនឹងមិនបើកផ្លូវដល់សមណគោតមទេ ។

ព្រះសម្មាសម្ពុទ្ធ កាលមិនបានផ្លូវពីសំណាក់នៃព្រះមាតុលា ក៏យាងត្រឡប់វិញ ។ ចំណែក ព្រះបាទសុប្បពុទ្ធ បានបញ្ជូនបុរសម្នាក់ទៅតាមយកការណ៍ តើព្រះសមណគោតម ត្រាស់យ៉ាងម៉េចខ្លះ ។

ព្រះពុទ្ធ ទ្រង់យាងត្រឡប់វិញ ដោយមានព្រះភក្ត្រញញឹម ។ ព្រះអានន្ទ ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន តើ

មានហេតុការណ៍ដូចម្ដេច ? ព្រះពុទ្ធ ត្រាស់ថា ម្នាលអានន្ទ ព្រះបាទសុប្បពុទ្ធ បានបិទផ្លូវព្រះពុទ្ធដូចជាតថាគត មិនឲ្យនិមន្តទៅ ឈ្មោះថាបានធ្វើបាបកម្មធ្ងន់ណាស់ ចាប់ពីថ្ងៃនេះទៅ ៧ ថ្ងៃទៀត ព្រះបាទសុប្បពុទ្ធ នឹងត្រូវព្រះធរណីស្រូបនៅក្បែរជើងជណ្ដើរនៃប្រាសាទរបស់ព្រះអង្គ ។

ចារបុរស បានស្ដាប់ព្រះតម្រាស់នៃព្រះពុទ្ធ ដូចនោះហើយ វិលត្រឡប់ទៅក្រាបទូលរឿងនេះសព្វគ្រប់ថ្វាយ ព្រះបាទសុប្បពុទ្ធ។ ព្រះបាទសុប្បពុទ្ធ ត្រាស់ថា សមណគោតមពោលអ្វីមិនដែលខុសទេ ប៉ុន្តែ ម្ដងនេះ ទោះជាយ៉ាងណាក៏ដោយ អាត្មាអញ នឹងចាប់កំហុសក្នុងការនិយាយមិនពិតឲ្យបាន ព្រោះផែនដីមិនអាចស្រូបអាត្មាអញបានទេ បើអាត្មាអញ មិនទៅកាន់ទីកន្លែងក្បែរជើងជណ្ដើរនោះ ។

ព្រះបាទសុប្បពុទ្ធ បញ្ជាពួកអមាត្យឲ្យជញ្ជូនគ្រឿងប្រដាប់គ្រប់មុខ សំរាប់ព្រះអង្គ យកទៅទុកក្នុងប្រាសាទជាន់ទី ៧ ឲ្យដោះជណ្ដើរ ឲ្យបិទទ្វារ និង ចាត់តាំងបុរសខ្លាំងៗ ប្រចាំគ្រប់ទ្វារ ក្នុងទ្វារមួយ ២ នាក់ ហើយត្រាស់ថា បើព្រះអង្គចង់ចុះទៅក្រោមដោយសេ្ដចក្ដីប្រមាទ អ្នកទាំង

ឡាយ ត្រូវហាមឃាត់ និង ចាប់ព្រះអង្គឡើងមកលើវិញ ហើយព្រះអង្គស្តេចគង់នៅក្នុងបន្ទប់ដ៏មានសិរី នៃ ប្រាសាទជាន់ទី ៧ នោះឯង ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធ មិនមែនគង់តែក្នុងប្រាសាទប៉ុណ្ណោះទេ ទោះជាហោះឡើងទៅគង់ក្នុងអាកាសក្តី ក្នុងសមុទ្រក្តី ក្នុងចន្លោះភ្នំក្តី, ធម្មតាតម្រាស់នៃព្រះពុទ្ធ មិនអាចទៅជា ២ យ៉ាងបានទេ, ទ្រង់នឹងត្រូវ ព្រះ-ធរណី ស្រូបត្រង់កន្លែងដែលតថាគត ពោលទុកនោះឯង, កាលទ្រង់ តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថា នេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតេ សោ ជគតិប្បទេសោ**
**យត្ថដ្ឋិតំ នប្បសហេយ្យ មច្ចុ ។**

បុគ្គលស្ថិតនៅក្នុងចន្លោះអាកាសក្តី ក្នុងកណ្តាលសមុទ្រក្តី ក្នុងចន្លោះភ្នំក្តី មិនអាចគេចផុតពីមច្ចុរាជ គឺសេចក្តីស្លាប់ បានទេ ព្រោះថា ប្រទេសគឺផែនដីដែលបុគ្គលស្ថិតនៅ

ហើយ មច្ចុរាជ មិនគ្របសង្កត់នោះ មិនមានទេ ។

ក្នុងថ្ងៃជាគម្រប់ ៧ ពេលវេលាប្រហែលគ្នា នឹងពេលដែលព្រះបាទសុប្បពុទ្ធ បិទផ្លូវព្រះសម្មាសម្ពុទ្ធនោះដែរ សេះមង្គលរបស់ព្រះបាទសុប្បពុទ្ធ បានស្រែកកញ្ជៀវឡើងយ៉ាងខ្លាំង ។ ព្រះបាទសុប្បពុទ្ធ ត្រាស់សួរថា សម្លេងអ្វីហ្នឹង ? អមាត្យ ទូលថា សេះមង្គលរបស់ព្រះអង្គ ស្រែកកញ្ជ្រោលខ្លាំងណាស់ ។ ព្រះបាទសុប្បពុទ្ធ មានបំណងនឹងចាប់សេះនោះ ក៏ក្រោកបែរព្រះកក្រ្តឆ្ពោះទៅរកទ្វារ ទ្វារក៏របើកជណ្តើរក៏មានព្រម បុរសចាំទ្វារក៏ចាប់រុញព្រះអង្គចុះក្រោមគ្រប់ៗទ្វារជាលំដាប់ រហូតដល់កន្លែងជើងជណ្តើរនៃប្រាសាទជាន់ក្រោមបំផុត ។ ព្រះធរណី ក៏បែកជា ២ ស្រូបយកព្រះ-បាទសុប្បពុទ្ធ ទ្រង់ក៏បានទៅកើតក្នុងឋាននរកអវចីនោះឯង[៩] ៕

## នត្ថិ កម្មសមំ ពលំ

មិនមានកម្លាំងអ្វី ខ្លាំងស្មើកម្លាំងកម្ម ។

---

[៩]-ធម្មបទដ្ឋកថា ភាគ ៥

# ពិចារណារឿយ ៗ

សម្មាសម្ពុទ្ធសម្តែងថា          ស្រ្តីក្តីណាឬបុរស
ទោះបព្វជិតឬគ្រហស្ថ          ទាំងអស់គប្បីពិចារណា ។
អាត្មាអញមានចាស់ជរា          ប្រែប្រួលគ្រាំគ្រាជាធម្មតា
មិនអាចគេចទៅកាន់ទីណា          ផុតពីជរាទៅបានឡើយ ។
អាត្មាអញតែងមានជម្ងឺ          តម្កាត់មុតឈឺមិនស្បូវស្បើយ
ឈឺក្បាលវិលមុខចុកចាប់ហើយ          លោកអ្នកនាងអើយឈឺគ្រប់គ្នា ។
អាត្មាអញត្រូវមានក្តីស្លាប់          ទោះយូរឬឆាប់គង់តែវា
មកដល់មិនខានហួសការពារ          ឲ្យផុតពីវាបានឡើយណា ។
អាត្មាអញត្រូវតែព្រាត់ប្រាស          និរាសចាកសត្វ និង សង្ខារ
ជាទីស្រឡាញ់ពេញចិន្តា          វាប្រែក្រឡាឃ្លាតឃ្លាទៅ ។
អាត្មាអញមានកម្មធម្មតា          ដោយកាយវាចាចិត្តតាំងនៅ
នាំកាយវាចាធ្វើការទៅ          ជួនខុសជួនត្រូវចម្រុះគ្នា ។
កម្មគឺជាទ្រព្យរបស់ខ្លួន          ស្ថិតនៅជាប់ជួនរាល់វេលា
ថ្ងៃយប់សុខទុក្ខជាមួយគ្នា          មិនដែលឃ្លាតឃ្លាគ្រាណាឡើយ។
តាំងពីជាតិនេះដល់ជាតិមុខ          កម្មរក្សាទុកនៅកៀកកើយ
ជាប់គ្នាជានិច្ចមិនឃ្លាតឡើយ          គឺកម្មនេះហើយរបស់ខ្លួន ។
កម្មជាអ្នកបង្កើតមនុស្ស          ត្រកូលទាបខ្ពស់យ៉ាងសមសួន
តាមកម្លាំងកម្មរបស់ខ្លួន          សុខទុក្ខផ្សេងៗយុត្តិធម៌ ។

កម្មទុកជាសាច់ញាតិសន្តាន ទោះបីយើងមានឬមួយក្រ
មិនបាច់ហាមាត់សុំអង្វរ មានក្តីស្មោះសរជួយពិតៗ ។
កម្មជាទីពឹងដ៏ប្រសើរ សំរាប់ដំណើរនៃជីវិត
បើធ្វើកម្មល្អកុំភ័យកិត កម្មជួយជីវិតពិតបានសុខ ។
យើងអ្នកទទួលផលនៃកម្ម ចូរបេះចងចាំកម្មគ្រប់មុខ
កម្មណាអាក្រក់ឲ្យជាទុក្ខ បានផលជាសុខព្រោះកម្មល្អ ។
បើយើងធ្វើនូវកម្មឯណា ល្អអាក្រក់ម្តេចម្តាខ្មៅឬស
វានឹងបញ្ចេញផលបន្ត ផលនោះយើងក៏ត្រូវទទួល ។៚

បើអស់លោកអ្នក សទ្ធាជឿជាក់ លើព្រះសាស្តា
គប្បីខិតខំ ពិចារណា ធម៌ប្រាំប្រការ
នេះឲ្យរឿយៗ ។
ព្យាយាមរិះគិត សំកីពិនិត្យ កុំខ្លាចហត់នឿយ
ពិចារណ៍យូរទៅ ឃើញធម៌រឿយៗ បដិបត្តិជឿយៗ(១០)
នឹងកើតបញ្ញា ។

---

(១០)-តាំងចិត្តជាឧបេក្ខា បដិបត្តិរឿយៗ ។

ដឹងច្បាប់ធម្មជាតិ ដែលព្រះលោកនាថ ហៅថាសង្ខារ
ផ្សំគ្នាកើតឡើង តាមធម្មតា មានចាស់ជរា
និង មរណៈ ។

នេះធម្មតាទេ ទាំងយើងទាំងគេ មិនគួរផ្អើលភ្ញាក់
ដឹងច្បាប់ធម្មជាតិ នេះប្រាកដជាក់ ឈប់លែងផ្អើលភ្ញាក់
ភ័យខ្លាចទៀតហើយ ។

មានកើតមានស្លាប់ ទុកដូចជាប្រាប់ ព្រាត់មិនខានឡើយ
បើចេះការពារ យូរយារអ្នកអើយ ព្រាត់មកដល់ហើយ
មិនសូវទុក្ខពេក ។

គិតរឿយៗទៅ បញ្ញារឹតជ្រៅ កើតធម្មសង្វេគ
ស្រឡាញ់ខ្លួនពិត មិនគួរឃ្លានស្រេក លោភលន់អ្វីពេក
បាបអកុសល ។

ដឹងច្បាស់ឃើញច្បាស់ ព្រះពុទ្ធទ្រង់ត្រាស់ រឿងកម្មនិងផល
រត់មិនរួចទេ យើងគេឈប់ឆ្ងល់ វាគង់តែផ្តល់
ផលវិញពុំខាន ។

ហិរិឱត្តប្ប : សទ្ធាជឿជាក់ ចាប់ធ្វើសីលទាន
ចំរើនភាវនា បញ្ញាកើតមាន មគ្គទុកជាយាន
សានសុខលោកិយ ។

បដិបត្តិច្រើន ចិត្តរឹតចំរើន បញ្ញាដុះថ្មី
ចាកបុថុជ្ជន ចូលដល់អរិយ មគ្គកើតឡើងថ្មី
កាត់កិលេស បាន ៗ

លះសំយោជនៈ អនុសយៈ កិលេសប៉ុន្មាន
ដាច់អស់ល្អើង ស្ងួតឆេងឥតមាន ចិត្ត បានសុខសាន្ត
ចូលនិព្វានហោង ។ល៚

# នត្ថិ សន្តិបរំ សុខំ

## សេចក្ដីសុខ ក្រៅលែងជាងព្រះនិព្វាន មិនមាន ។

## ធម៌ចុងវត្ត

កិច្ចដែលព្រះសង្ឃគប្បីធ្វើ ហៅថា វត្ត ។ វត្តមានច្រើន ប៉ុន្តែ ក្នុងទីនេះ សំដៅយក វត្តព្រឹក វត្តល្ងាច ។ កិច្ចនមស្សការ ថ្វាយបង្គំព្រះរតនត្រ័យពេលព្រឹក ហៅថា វត្តព្រឹក, កិច្ចនមស្សការ ថ្វាយបង្គំព្រះរតនត្រ័យពេលល្ងាច ហៅថា វត្តល្ងាច ។ ធម៌មួយចំនួនសំរាប់សូត្រខាងចុងបន្ទាប់ពីបទនមស្សការថ្វាយបង្គំព្រះរតនត្រ័យព្រឹកល្ងាច ដើម្បីពិចារណាឲ្យកើតធម្មសង្វេគ និង ដើម្បីរំលឹកដាស់តឿនស្មារតី ឲ្យភ្ញាក់រលឹក ខំប្រឹងប្រែងបដិបត្តិធម៌ច្រើនឡើងៗ ហៅថា ធម៌ចុងវត្ត ។ ខ្ញុំ នឹងលើកយកធម៌ចុងវត្តខ្លះ មកសរសេរទុកក្នុងទីនេះ ដើម្បីជូនពុទ្ធបរិស័ទ សិក្សាបដិបត្តិដូចតទៅ ។

## អភិណ្ហប្បច្ចវេក្ខណ

**ជរាធម្មោម្ហិ ជរំ អនតីតោ** អាត្មាអញ[៨] មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ។

---

(៨)– ម្នាក់ឯងសូត្រថា អាត្មាអញ ពីរនាក់ឡើងទៅ សូត្រថា យើង ។

ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ។

មរណធម្មោម្ហិ មរណំ អនតីតោ អាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ។

សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្មាអញ មានសេចក្តីព្រាត់ប្រាសចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ។

កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ គឺអ្នកទទួលនូវមត៌កនៃកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹងអាស្រ័យ អាត្មាអញនឹងធ្វើនូវកម្មណា ល្អក្តី អាក្រក់ក្តី នឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ។

ឯវំ អម្ហេហិ អភិណ្ហំ បច្ចវេក្ខិតព្វំ យើងទាំងឡាយគប្បីពិចារណារឿយៗយ៉ាងនេះឯង ៕

## ទ្វត្តឹសាការ អាការៈ ៣២

អយំ ខោ មេ កាយោ កាយរបស់អាត្មាអញនេះឯង ឧទ្ធំ បាទតលា ខាងលើអំពីបាទជើងឡើងទៅ អធោ កេសមត្ថកា ខាងក្រោមអំពីចុងសក់ចុះមក តចបរិយន្តោ មានស្បែកព័ទ្ធជុំវិញ បូរោ នានប្បការស្ស អសុចិនោ ពេញដោយរបស់មិនស្អាតមានបការៈផ្សេងៗ អត្ថិ ឥមស្មឹ កាយេ មានក្នុងកាយនេះ កេសា សក់ទាំងឡាយ លោមា រោមទាំងឡាយ នខា ក្រចកទាំងឡាយ ទន្តា ធ្មេញទាំងឡាយ តចោ ស្បែក មំសំ សាច់ ន្ហារូ សរសៃទាំងឡាយ អដ្ឋី ឆ្អឹងទាំងឡាយ អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង វក្កំ តម្រងទឹកនោម ហទយំ បេះដូង យកនំ ថ្លើម កិលោមកំ វាវ បិហកំ លំពែង បប្ផាសំ សួត អន្តំ ពោះវៀនធំ អន្តគុណំ ពោះវៀនតូច ឧទរិយំ អាហារថ្មី ករីសំ អាហារចាស់ បិត្តំ ប្រមាត់ សេម្ហំ ស្លេស្ម បុព្វោ ខ្ទុះ លោហិតំ ឈាម សេទោ ញើស មេទោ ខ្លាញ់ខាប់ អស្សុ ទឹកភ្នែក វសា ខ្លាញ់រាវ ខេឡោ ទឹកមាត់ សិង្ឃាណិកា ទឹកសម្បោរ លសិកា ទឹករំអិល

មុត្តំ ទឹកមូត្រ មត្ថកេ មត្ថលុង្គំ ខួរក្នុងក្បាល ឯវមំ អយំ មេ កាយោ ឥតិ យើងទាំងឡាយ គប្បីពិចារណា យ៉ាងនេះឯង ។

## មរណស្សតិ

អទ្ធុវំ មេ ជីវិតំ ជីវិតរបស់អាត្មាអញមិនទៀង ។

ធុវំ មរណំ សេចក្តីស្លាប់ទៀង ។

អវស្សំ មយា មរិតព្វំ អាត្មាអញ ត្រូវតែស្លាប់ ដោយពិត ។

មរណបរិយោសានំ មេ ជីវិតំ ជីវិតរបស់អាត្មាអញ មានសេចក្តីស្លាប់ជាទីបំផុត ។

ជីវិតំ អទ្ធុវំ ជីវិតមិនទៀង ។

ធុវំ មរណន្តិ សេចក្តីស្លាប់ទៀង ។

## ភារសុត្តគាថា

ភារា ហវេ បញ្ចក្ខន្ធា បញ្ចក្ខន្ធ ជាភារៈដ៏ធ្ងន់ហ្ន៎ !

ភារហារោ ច បុគ្គលោ បុគ្គលជាអ្នកនាំទៅនូវភារៈដ៏ធ្ងន់

ភារាទានំ ទុក្ខំ លោកេ ការកាន់យកនូវភារៈដ៏ធ្ងន់ជាទុក្ខ ក្នុងលោក ភារនិក្ខេបនំ សុខំ ការរលាស់ចោលនូវភារៈដ៏ធ្ងន់ ជាសេចក្ដីសុខ និក្ខិបិត្វា គរុំ ភារំ ព្រះអរិយរលាស់ចោលនូវភារៈដ៏ធ្ងន់ហើយ អញ្ញំ ភារំ អនាទិយ មិនកាន់យកនូវភារៈដ៏ធ្ងន់ដទៃទៀតឡើយ សមូលំ តណ្ហំ អព្ពុយ្ហ បានដកចោលហើយនូវតណ្ហា ព្រមទាំងឫសគល់ និច្ឆាតោ បរិនិព្វុតោតិ ជាអ្នកអស់សេចក្ដីប្រាថ្នា បរិនិព្វានហើយ ។

## តិលក្ខណគាថា

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ ក្នុងកាលណា បុគ្គលឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង មិនទៀង អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ក្នុងកាលនោះ គេរមែងនឿយណាយក្នុងទុក្ខនុ៎ះ ជាផ្លូវនៃសេចក្ដីបរិសុទ្ធិពិសេស គឺព្រះនិព្វាន ។

សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ ក្នុងកាលណា បុគ្គលឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង ជាទុក្ខ អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ

ផិសុទ្ធិយា ក្នុងកាលនោះ គេរមែងនឿយណាយក្នុងទុក្ខ ទ៌ុះ ជាផ្លូវនៃសេចក្តីបរិសុទ្ធិពិសេស គឺព្រះនិព្វាន ។

សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ ក្នុងកាលណា បុគ្គលឃើញដោយបញ្ញាថា ធម៌ទាំងឡាយ ទាំងពួង ជាអនត្តា អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ ផិសុទ្ធិយា ក្នុងកាលនោះ គេរមែងនឿយណាយក្នុងទុក្ខ ទ៌ុះ ជាផ្លូវនៃសេចក្តីបរិសុទ្ធិពិសេស គឺព្រះនិព្វាន ។

## បច្ឆិមវាចា

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតតឿនអ្នកទាំងឡាយថា វយធម្មា សង្ខារា សង្ខារទាំងឡាយ មានការអស់ទៅជាធម្មតា អប្បមាទេន សម្បាទេថាតិ អ្នកទាំងឡាយ ចូរញ៉ាំងសេចក្តីមិនប្រមាទឲ្យដល់ព្រមចុះ ។ អយំ តថាគតស្ស បច្ឆិមា វាចា នេះជាវាចាចុងក្រោយបំផុត របស់តថាគត ៕

# សំណួរ ចម្លើយ

៣៩៧

ស-អ្នកខ្លះនិយាយថា ខ្មែរយើង ធ្វើបុណ្យច្រើនណាស់ ម៉េចក៏យើង មិនបានសុខ ?

ច-អ្នកកាន់ពុទ្ធសាសនា ថេរវាទ គេធ្វើបុណ្យស្របជៀងៗគ្នានឹងខ្មែរយើងដែរ ខ្មែរយើងធ្វើ... ណាស់ ឬ មិនណាស់ ពិនិត្យមើលឲ្យច្បាស់ ខ្លួនឯងទៀតទៅ កុំជឿតែគេនិយាយ ។ វិធីនាំឲ្យបានបុណ្យមាន ៣ គឺ ទាន សីល ភាវនា តើខ្មែរយើងបានធ្វើគ្រប់ទាំង ៣ នេះឬទេ ? ទាន សីល ភាវនា របស់ខ្មែរយើង មានគុណភាពដូចម្តេចដែរ ? អ្នកធ្វើបុណ្យត្រូវមានបុណ្យក្នុងខ្លួន តើខ្មែរយើង មានចិត្តសប្បុរស ស្មោះត្រង់ រាប់អានគ្នា អាណិតគ្នា ជួយគ្នា មានកម្រិតណាដែរ ? អ្នកធ្វើបុណ្យត្រូវមានសទ្ធា... និង... បញ្ញា ចុះបើគេធ្វេចភ្នែកធ្វើ... ធ្មេចភ្នែកមិនធ្វើ... តើបានអ្វីជាតួនាំគេទៅរកសេចក្តីសុខ ? ពិចារណាឲ្យយល់រឿងទាំងអស់នេះទៅ គេនឹងយល់បានខ្លះ នូវហេតុដែលនាំឲ្យខ្មែរយើងមិនបានសុខនោះ ។

៥-ធម៌ថា ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់ ខ្ញុំធ្វើបុណ្យសន្ធឹក ប៉ុន្តែ ខ្ញុំជួបតែទុក្ខ... មិនឃើញបុណ្យជួយខ្ញុំសោះ ។ ឥឡូវ ខ្ញុំលែងជឿ កម្ម ផល លែងធ្វើបុណ្យ តើវាយ៉ាងម៉េចទៅ ?

៦-បុណ្យគឺសេចក្ដីល្អ បើគេមិនធ្វើល្អ ហើយនាំគមកធ្វើអាក្រក់ ជារឿងមួយគួរឲ្យព្រឺខ្លួននិងរន្ធត់ជាទីបំផុត ព្រោះអំពើអាក្រក់ វាមិនដែលបាត់ទៅណាទេ វាត្រូវតែឲ្យផលជាទុក្ខលំបាកមកវិញជាដរាប ទោះឆាប់ ឬ យូរយ៉ាងណាក៏ដោយ ។ បើជឿថា សុខ ទុក្ខ ព្រះអាទិទេព ជាអ្នកឲ្យ តើព្រះអាទិទេព នៅទីណា ? គួរគោរពតទៅទៀតឬទេ ? បើលោកឲ្យសុខទៅគេ ហើយឲ្យទុក្ខមកយើង តាមអំពើចិត្តរបស់លោកយ៉ាងនេះ ។ បើជឿថា សុខ ទុក្ខ បានមកដោយចៃដន្យ តើចំណេះវិជ្ជា ទ្រព្យសម្បត្តិ... និង សេចក្ដីរាប់អានជាដើម សុទ្ធតែបានមកដោយចៃដន្យដែរឬ ? យើងត្រូវនៅស្ងៀម ដេករង់ចាំចៃដន្យឬ ? មនុស្សមានបញ្ញា គេមិនធ្វើដូចនោះទេ គេត្រូវតែឈប់ធ្វើសេចក្ដីអាក្រក់ ហើយខំប្រឹងធ្វើសេចក្ដីល្អ ដោយខ្លួនឯង ។ ឯរឿងអ្នកធ្វើបុណ្យ ហើយមិន-

ឃើញបុណ្យជួយ មិនមែនប្រែថា គ្មានបុណ្យ ឬ បុណ្យមិនឲ្យផលនោះទេ ប៉ុន្តែ ពេលវេលារបស់វាមិនទាន់ដល់... ព្រោះបុគ្គលម្នាក់ៗ ធ្វើបុណ្យ បាប ល្អ អាក្រក់ ជំពាក់ទាក់ទាមគ្នាច្រើនណាស់ រាប់ដោយអសំខេយ្យជាតិ គេនឹងទាមទារឲ្យស៊ីសងគ្នាទាន់ចិត្ត ត្រឹមតែមួយជាតិបច្ចុប្បន្ននេះ មិនបានទេ មិនត្រឹមត្រូវទេ ។ ត្រូវពិនិត្យមើល បញ្ជាក់ផង ។

ស-កម្ម ផល និង ហេតុ ផល ដូចគ្នាឬទេ ?

ច-ស្រដៀងគ្នា កម្ម គឺអំពើដែលគេធ្វើ ប្រកបដោយចេតនា អំពើដោយកាយ ហៅថា កាយកម្ម អំពើដោយវាចា ហៅថា វចីកម្ម អំពើដោយចិត្ត ហៅថា មនោកម្ម ។ ផល គឺអ្វីដែលកើតអំពីកម្មនោះ ឧទាហរណ៍ អំពើសម្លាប់គេ ហៅថា កម្ម ។ ដោយសារសម្លាប់គេ ត្រូវប៉ូលិសចាប់ដាក់គុកក្តី ឬបន្ទាប់ពីស្លាប់ ទៅកើតក្នុងអបាយភូមិក្តី នេះ ជាផល ។

ចំណែក ហេតុ គឺអ្វីដែលកើតមានហើយ ទោះបីជាវត្ថុក្តី ជាអំពើក្តី ប្រកបដោយ ចេតនា ឬ មិនប្រកបដោយចេតនាក្តី ឲ្យតែកើតមានហើយ បណ្តាលឲ្យកើតជាអ្វីទៀតបាន ហៅថា ហេតុ ទាំងអស់ ។

៦ផល គឺអ្វីដែលកើតអំពីហេតុនោះ ឧទាហរណ៍ អំបិល ជាហេតុ សាច់ប្រៃក្តី សាច់មិនស្អុយក្តី នេះជាផល ។ ហេតុផល មានតួនាទីទូលាយជាង កម្ម ផល ឬ និយាយថា កម្ម ផល ជាផ្នែកមួយ នៃ ហេតុ ផល ដូចនេះ ក៏បាន ។

ព្រះពុទ្ធ សម្តែងថា ធម៌ទាំងឡាយ កើតមកពីហេតុ មានហេតុ ទើបកើតឡើងបាន ទើបតាំងនៅបាន ហេតុប្រែប្រួល ផលត្រូវតែប្រែប្រួល ហេតុរលត់ ផលត្រូវតែរលត់ ។

ស-អភិណ្ហបច្ចវេក្ខណធម៌ ជាអារម្មណ៍របស់ សមថៈ ឬ ជាអារម្មណ៍របស់ វិបស្សនា ?

ឆ-ព្រះពុទ្ធ បានសម្តែងថា ចំរើនធម៌ ៥ ប្រការនេះច្រើនឡើងៗ កិលេសស្រាលស្តើង អស់ទៅៗ រហូតដល់អស់សំយោជនៈ បានសម្រេច មគ្គ ផល ព្រះនិព្វាន ។ ព្រះអង្គ មិនបានកំណត់ទុកថា ជាអារម្មណ៍របស់ សមថៈ ឬ វិបស្សនា ឡើយ ។ ប៉ុន្តែ បើពិចារណាលើគោលធម៌នេះហើយ យើងអាចយកជាអារម្មណ៍ ដើម្បីអប់រំចិត្តឲ្យស្ងប់ជា សមថៈ ក៏បាន ដើម្បីអប់រំចិត្តឲ្យមានបញ្ញាជា វិបស្សនា

ក៏បាន ឥតមានអ្វីទាស់ខុសទេ ។

ស-អ្នកខ្លះថា សមថៈ មិនបាច់ចំរើនទេ នាំតែបុកខ្នង បង្អេះ និង ខាតពេលឥតប្រយោជន៍ ចំរើនតែវិបស្សនា ក្នុង ជីវិតប្រចាំថ្ងៃ គឺចាំមើលអារម្មណ៍ដែលចូលមកតាមទ្វារភ្នែក ត្រចៀក... ប៉ុណ្ណោះ នៅផ្ទះរៀងៗខ្លួនបានហើយ មិនបាច់ទៅ រកធម៌ឯណាទៀតទេ ។ តើយ៉ាងម៉េចដែរ ?

ច-ព្រះពុទ្ធ សម្តែងថា ធម៌ ២ គឺ ១-សមថៈ ២-វិបស្សនា ជាធម៌ត្រូវចំរើន ជាធម៌នាំឲ្យកើតវិជ្ជា កើត បញ្ញា... ។ ឯអ្នកបដិបត្តិ បើចំរើនទាំង ២បានផលល្អ ចំរើនទៅ.. បើចំរើនតែវិបស្សនា បានផលល្អ ចំរើនទៅ... ប៉ុន្តែ កុំលុបបំបាត់ធម៌របស់ព្រះពុទ្ធ និង កុំមើលងាយអ្នក ធ្វើសមថៈ នាំឲ្យកើតបាប ។

អ្នកមិនចូលចិត្តធ្វើសមថៈ មើលទៅឃើញតែខុសនិង ខាត របស់អ្នកធ្វើសមថៈ ប៉ុន្តែ អ្នកប្រាជ្ញទាំងឡាយ ឃើញ ច្បាស់ថា កម្មវិធី កតិកា វិន័យ ខន្តិ និង វីរភាព ក្នុងការហ្វឹក ហាត់ធ្វើសមថៈ (សមាធិ) នោះឯង ដែលកសាងមនុស្ស និង ជួយបណ្តុះឲ្យមានបញ្ញា ។

ព្រះពុទ្ធ សម្តែងថា

**-សីលបរិភាវិតោ សមាធិ** សមាធិ មានសីលអប់រំល្អ ហើយជាគ្រឿងទ្រ មានផលច្រើន មានអានិសង្សច្រើន

**-សមាធិបរិភាវិតា បញ្ញា** បញ្ញា មានសមាធិអប់រំល្អ ហើយ ជាគ្រឿងទ្រ មានផលច្រើន មានអានិសង្សច្រើន

**-បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ** ចិត្តដែលមានបញ្ញាអប់រំល្អហើយជាគ្រឿងទ្រ រមែងរួចចាក អាសវៈទាំងឡាយ ដោយប្រពៃ ។

**និដ្ឋិតំ**

**ចប់ហើយ**

## លោក អ្នក សប្បុរស ដែលបានជួយឧបត្ថម្ភការបោះពុម្ព

| | |
|---|---|
| ១-លោក ង្វី ហុក និង ភរិយា | ២០ € |
| ២-លោក ណុប ពុទ្ធីរ៍ និង គ្រួសារ | ២០ € |
| ៣-ឧបាសក ណៃ ហួរ | ២០ € |
| ៤-អាចារ្យ មិន ជូ ឧបាសិកា តាំង រួចប៉ោ | ២០ € |
| ៥-ឧបាសិកា គុល ទូច | ៥០ € |
| ៦-ឧបាសិកា ឡាយ រិុ | ៤០ € |
| ៧-លោកស្រី ឡេាត គីរីកញ្ញា និង អេឌ័រ | ៥០ € |
| ៨-ឧបាសក តាន់ ណាំ ឧបាសិកា លិម ឆេងអុី | ៥០ $ |
| ៩-ឧបាសិកា នេត្រ គួន | ២០ € |
| ១០-ឧបាសិកា ស៊ីសុវត្ថិ ក្រិត្យ នារី | ២០ € |
| ១១-ឧបាសិកា ឈា ឡេង ហាក់ | ២០ € |
| ១២-ឧបាសិកា ម៉ា វណ្ណា និង បុត្រធីតា | ២០ € |
| ១៣-ឧបាសិកា ហុង និន និង អ្នកស្រី តង | ៥០ € |
| ១៤-អ្នកស្រី គីម មួយ | ២០ € |
| ១៥-លោក លីម ហ៊ុយគៀង អ្នកស្រី ម៉ៅ ទៀង | ៥០ $ |

១៦-លោក ដាក់ ២០ €

១៧-លោក ជួន ទឹម អ្នកស្រី ទិត ពៅ ២០ €

១៨-លោកស្រី ប៉ុន ហ៊ុនគី ២០ €

១៩-លោក និង លោកស្រី ចៅ សាវុទ្ធី ព្រមទាំងបុត្រ ២០ €

២០-ឧបាសិកា មួន សារ៉ាត់ និង កូនចៅ ៤០ €

២១-លោក ប៉ែន ពិសិដ្ឋ និង ភរិយា ១០០ $

២២-អ្នកស្រី អ៊ា ទុង ហួង និង បុត្រធីតា ១០០ $

២៣-ឧបាសិកា ចាន់ ហៀន ១០០ $

២៤-លោក ជឿន ៥០ €

២៥-លោក សួង ណារឿន និង ភរិយា ២០ €

២៦-Mr et Mme NGO CHINTEK ២០ €

២៧-អ្នកស្រី កែវ សុវណ្ណា ១០ €

២៨-លោក អ៊ុំ ច័ន្ទវាសនា អ្នកស្រី អ៊ុំ ធវ័ន្ត ២០ €

២៩-ឧបាសិកា យក់ លាន ២០ €

៣០-ឧបាសិកា គាត ស៊ូរី ២០ €

៣១-អ្នកស្រី ទេព ម៉ាលិស ១០ €

៣២-លោក ប៉ុក ស៊ីមហៃ ២៥ €

៣៣-លោក ខៀវ ឡេង និង ភរិយា ៥០ €

៣៤-ឧបាសិកា លី ឈុនស៊ី ៥០ €

៣៥-ឧបាសក ប៉ុន គង់ ឧបាសិកា បៃណាងសៀង ៣០ €

៣៦-ឧបាសិកា នៅ ទាវខេង និង បុត្រធីតា ២០ €

៣៧-ឧបាសិកា ណែម លិមអ៊ាន ២០ €

៣៨-ឧបាសិកា ណែម លិមអ៊ុន ២០ €

៣៩-ឧបាសិកា ឈា ឆេងលន់ ២០ €

៤០-ឧបាសិកា ឃី អេង ឡាំ ២០ €

៤១-ឧបាសិកា អ៊ុង អាង ២០ €

៤២-ឧបាសិកា អៀង ហុង ១៥ €

៤៣-ឧបាសិកា ប៉ុន ហ៊ុលឃុត ១៥ €

៤៤-ឧបាសិកា ឃិន ហុកទីវ ១៥ €

៤៥-ឧបាសិកា សុត សុផានី ១៥ €

៤៦-ឧបាសិកា អាត អេង ១៥ €

៤៧-ឧបាសិកា សៀប គីមហ៊ាង ១៥ €

៤៨-ឧបាសិកា គួ អៀទី ១៥ €

៤៩-ឧបាសិកា ជូ ម៉ាក់ ១៥ €

៥០-ឧបាសិកា តាំង អ៊ុម ១៥ €

៥១-ឧបាសិកា គីម សួផន ១៥ €

៥២-ឧបាសិកា ទី វណ្ណហាង្ស ១៥ €

៥៣-ឧបាសិកា សេក ហេង ១៥ €

៥៤-លោក អ៊ុន សារ៉េន និង ភរិយា ១៥ €

៥៥-ឧបាសិកា អ៊ុំ យេន ១៥ €

៥៦-ឧបាសិកា ទា គីមលី ១៥ €

៥៧-ឧបាសិកា ទា គីមលន់ ១៥ €

៥៨-លោក និង អ្នកស្រី ស៊ាម ហ៊ុច ១៥ €

៥៩-លោក និង អ្នកស្រី កៀវ ម៉ារី និង បុត្រធីតា ១៥ €

៦០-លោក ទេព សំផន និង ភរិយា ១៥ €

៦១-ឧបាសក ឡៅ ហេង ឧបាសិកា តាន់ សាយយុត ១៥ €

៦២-អ្នកស្រី ឡៅ សាយ យីម ១៥ €

៦៣-អ្នកស្រី ជីប ហុងយ៉េន ១៥ €

៦៤-លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ €

៦៥-អ្នកស្រី ឡៅ ហុងស៊ីម និង បុត្រធីតា ១៥ €

៦៦-ផុន សុទីថា និង ស៊ុន ណារ៉េត ១៥ €

៦៧-ឧបាសិកា ញ៉ឹក សាយ៉ាន់ ១៥ €

៦៨-អ្នកស្រី ប៉ាវ សារ៉េន និង ធីតា ១៥ €

៦៩-លោក និង អ្នកស្រី ឱម ស៊ីថា ១៥ €

៧០-អាចារ្យ ញាណ ឆាន និង ភរិយា ១៥ €

៧១-លោក ខូវ ឡាយអាន និង អ្នកស្រី គីម គុន ១៥ €

៧២-ឧបាសិកា អ៊ឹង ម៉ាឡេង ១៥ €

៧៣-លោកស្រី ជាវ ស៊ីវហួង ១៥ €

៧៤-ភិក្ខុ ងិន កេន ២០ €

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះ លោក អ្នក ដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និងមាតាបិតាជាដើម ព្រមទាំងញាតិមិត្រទាំងឡាយ ។ សូម លោក អ្នក ដ៏មានគុណទាំងឡាយ ជាដើមនោះ អនុមោទនា ចំពោះបុណ្យកុសលនេះ ហើយទទួលនូវឥដ្ឋមនុញ្ញផល ជាទី គាប់ចិត្ត កុំបីអាក់ខានឡើយ ។ ៚

# កុំស្លាប់ដូចពស់...

កុំស្លាប់ដូចពស់រស់ដូចកង្កែប
ពួនទៅអបអែបក្បែរគល់គុម្ពផ្កា
តែវាមិនដឹងក្លិនក្លែបគន្ធា
ចាញ់ភមរាដែលនៅទីឆ្ងាយ ។
ពស់ពេលរស់នៅមានពិសពន្លឹក
ជ្រួតជ្រាបដូចទឹកសព្វសព៌ាង្គកាយ
ពេលវាស្លាប់ទៅឆ្អឹងនៅអន្តរាយ
អាចមុតប្រែក្លាយជាពិសស្លាប់បាន ។
រស់នៅមិនគាប់ងាប់ទៅមិនគួរ
នាំឲ្យហ្មងមួអួអាប់រំខាន
មិនដែលសាងឲ្យគេបានសុខសាន្ត
ទើបចាស់បុរាណពោលទុកច្បោះឯង ។
យើងជាមនុស្សកុំយកតម្រាប់
ដូចសត្វអកព្វរស់ងាប់ចំបែង
ត្រូវខំព្យាយាមតស៊ូស្វះស្វែង
សាងឲ្យគេឯងបានសុខសព្វកាល ៕៚